# ព្រឹត្តិបត្រកម្មវិធីកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ៣ | ឆ្នាំ២០១៦



# បុព្វកថា

ដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤។ ពេលនោះ គោលដៅចម្បងរបស់យើង គឺ“**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**” ដែលផ្តោតលើការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ យើងបានដាក់ចេញ និងជំរុញការអនុវត្តវិធានការជាច្រើន ដែលសំដៅជាសំខាន់លើការដោះស្រាយបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ។ បន្ទាប់ពីបានអនុវត្តអស់រយៈពេល ៤ ឆ្នាំ និងដោយពិនិត្យឃើញថា ភាពជឿទុកចិត្តនៃថវិកា ត្រូវបានសម្រេចជាមូលដ្ឋាន យើងក៏បានដាក់ចេញនូវ “**ដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**” នៅចុងឆ្នាំ២០០៨ ជាមួយនឹងគោលដៅចម្បងនៃ “**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**” ដោយផ្តោតជាសំខាន់លើការរៀបចំ ការកែលម្អ ព្រមទាំងការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដារអន្តរជាតិ។ យើងបានចាយពេលជាង ៦ ឆ្នាំ ក្នុងការត្រៀមរៀបចំសមាសភាគជាច្រើនសម្រាប់កសាង “**មូលដ្ឋានគ្រឹះនៃប្រព័ន្ធថវិកាថ្មី**” ដែលជា “**ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល**”។

ការចាប់ផ្តើមដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” បានបង្ហាញថាការកែទម្រង់របស់យើង បានឈានមកដល់ចំណុចមួយដ៏សំខាន់ នោះគឺដំណាក់កាលនៃការចាប់ផ្តើមធ្វើការផ្លាស់ប្តូរមួយចំណែកម្តងៗ នៃប្រព័ន្ធថវិកាបច្ចុប្បន្នដោយបានចាប់ផ្តើមពីចុងឆ្នាំ២០១៥ នេះ តាមរយៈការដាក់ឱ្យអនុវត្តនូវមាតិកាថវិកាថ្មី ស្តង់ដារគណនេយ្យ និងប្លង់គណនេយ្យថ្មី អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី១ ព្រមទាំងការចាប់ផ្តើមពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញ ជាជំហានៗ ទៅក្នុងចំណោមក្រសួង-ស្ថាប័នរដ្ឋ គ្រប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីឆ្នាំ២០១៥ទៅ រហូតដល់ឆ្នាំ២០១៨ ស្របតាម “**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០**” ក្នុងគោលដៅបោះជំហានឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកាទាំងស្រុងពី “**ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ**” ឱ្យបាននៅឆ្នាំ២០២០។ ការរៀបចំការផ្លាស់ប្តូរនេះ គឺជាការងារស្នូលនៃដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងដែលកំណត់យកការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាគោលដៅចម្បង។ បន្ទាប់មកទៀត តាមការគ្រោងទុកចាប់ពីឆ្នាំ២០២០ យើងនឹងបន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធថវិកាកម្មវិធីដែលផ្តោតលើលទ្ធផល ឬធាតុចេញនេះ ជាបណ្តើរៗ ឆ្ពោះទៅរក “**ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម**” នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលឱ្យបានសម្រេចនៅឆ្នាំ២ ០ ២ ៥ ដែលនេះគឺជាគោលដៅចម្បងនៃដំណាក់កាលចុងក្រោយ គឺ ដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បរិការណ៍កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើង បានចង្អុលប្រាប់យ៉ាងជាក់ប្រាកដថាការងារកែទម្រង់នេះ គឺជាមាគ៌ាដ៏ត្រឹមត្រូវតែមួយគត់ដែល **អគ្គមហាបុរស** នៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចជ្រើសរើសយកមកប្រតិបត្តិយ៉ាងតត្មត់ និងម៉ឺងម៉ាត់ក្លៀវក្លា តាមទស្សនវិស័យដ៏ប្រាកដនិយម គឺ “**កែទ ម្រង់គឺរ ស់ មិនកែ ទ ម្រង់គឺស្លាប់**”។ ហេតុនេះ យើងពិតជាគ្មានជម្រើសអ្វីផ្សេងឡើយ ក្រៅពីការខិតខំពុះពារជំនះការលំបាក និងឧបសគ្គសព្វសារពើ ដើម្បីអភិវឌ្ឍសមត្ថភាពដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបំពាក់ជាប់ជានិច្ចនូវស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ ចំពោះគោលដៅកែទម្រង់ដែលបានកំណត់ប្រកបដោយសតិសម្បជញ្ញៈ

នៃលក្ខណៈបន្ទាន់ មហិច្ឆតា និងប្រាកដនិយម នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាយើង។

ប្រាកដណាស់ ថវិកាកម្មវិធី គឺជាស្នូលនៃការកែទម្រង់ប្រព័ន្ធថវិកា នៅក្នុងដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលនឹងឈានមកដល់នៅឆ្នាំ២០១៦ ប៉ុន្តែការអនុវត្ត "**យុទ្ធសាស្ត្រកែទម្រង់ឆោះជំហានជាដំណាក់កាល**" បានបង្ហាញប្រាប់យើងថា កិច្ចការនេះ គឺជាជំហានទី៣នៃការកែទម្រង់ ដែលយើងបានរៀបចំត្រៀមខ្លួនបានជាច្រើនរួចមកហើយ នៅក្នុងដំណាក់កាលទី២ ហើយទាមទារជាចាំបាច់ឱ្យយើងត្រូវពង្រឹង និងបំពេញបន្ថែមទៀតទាំងក្នុងកម្រិតប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស។

ដើម្បីធានាបាននូវសុក្រឹតភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ថវិកា និងរចនាសម្ព័ន្ធស្ថាប័នគ្រប់គ្រងចាំបាច់ត្រូវពិនិត្យ និងកែលម្អបន្ថែម សំដៅបន្សុីគ្នា និងភ្ជាប់គ្នាជាមួយគោលបំណងគោលនយោបាយ ពោលគឺគម្លាតរវាងរចនាសម្ព័ន្ធស្ថាប័ន និងផែនការថវិកាជាមួយនឹងគោលនយោបាយ ត្រូវបានកាត់បន្ថយជាអតិបរមា។ ក្នុងទស្សនៈនេះ រចនាសម្ព័ន្ធគោលនយោបាយ នឹងត្រូវកំណត់ឱ្យបានជាក់ប្រាកដបន្ថែម ទាំងផ្នែកទំនាក់ទំនងអន្តរវិស័យ និ ងជាឋានានុក្រមគោលនយោបាយរវាងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ កម្មវិធីវិនិ យោគសាធារណៈ៣ឆ្នាំរំកិល ក្របខ័ណ្ឌថវិការយៈពេលមធ្យម ក្របខ័ណ្ឌចំណូល និងចំណាយរយៈពេលមធ្យម និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ។ សុខដុមនីយកម្មជាប្រព័ន្ធ លើការទំនាក់ ទំនង និងលំដាប់ឋានានុក្រមនៃបទដ្ឋានគោលនយោបាយទាំងនេះ គឺជាលក្ខខណ្ឌចាំបាច់ និងជាមូលដ្ឋានសម្រាប់ធ្វើការផ្សារភ្ជា ប់គោលបំណងគោលនយោបាយរបស់ក្រសួង- ស្ថាប័ននីមួយៗ ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលផង និងផ្សារភ្ជាប់ទៅនឹ ង គម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង- ស្ថាប័នផង។យន្តការសម្រាប់ធានាសុខដុមនីយកម្មនៃក្របខ័ណ្ឌគោលនយោបាយនេះ ចាំបាច់ត្រូវពិនិត្យ រៀបចំ និងកែលម្អបន្ថែម ដើម្បីធានាបាននូវសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង- ស្ថាប័ននីមួយៗ ប្រកបដោយលក្ខណៈភ្ជាប់គ្នាជាមួយនឹងការសម្រេចសមិទ្ធកម្មលើគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ម្យ៉ាងទៀត ជាមួយនឹងរចនាសម្ព័ន្ធគោលនយោបាយ ដែលត្រូវមានទំនាក់ទំនងភ្ជាប់គ្នា និងលំដាប់ឋានានុក្រមរវាងគ្នាកំណត់ជាក់លាក់ហើយនោះ រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន ក៏ត្រូវកំណត់ឱ្យបានជាក់លាក់ផងដែរអំពីមុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំក្រសួង អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យ ដែលនឹងត្រូវពិនិត្យលក្ខណៈសម្បត្តិ និងសមត្ថភាពក្នុងការផ្តល់ជូននូវមុខងារជាអង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកា ជាមួយនឹងសិទ្ធិអំណាចសមស្របក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួនទៅតាមកម្រិតកំណត់ដោយប្រធានស្ថាប័នដែលជាអាណាប័ក។ ក្នុងន័យនេះ ក្របខ័ណ្ឌនៃមុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវទាំងឡាយ គប្បីត្រូវបានកំណត់បន្ថែមឱ្យបានច្បាស់លាស់ ហើយក៏ត្រូវយកទៅសម្របទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង- ស្ថាប័ន នីមួយៗ សំដៅធានាឱ្យគម្រោងថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងដោយរំលេចឃើញកាន់តែច្បាស់នូវការចូលរួមប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ក្នុងការអនុវត្តមុខងារនិងភារកិច្ច ពីគ្រប់តួអង្គប្រតិបត្តិពាក់ព័ន្ធ អនុលោមតាមរចនាសម្ព័ន្ធគ្រប់គ្រង និងឆ្លុះបង្ហាញជាក់លាក់អំពីសមិទ្ធកម្មដែលត្រូវសម្រេចបានធៀបទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីដែលត្រូវបានកំណត់ដោយសាមីក្រសួង- ស្ថាប័ននីមួយៗ។

ជារួម ក្នុងគោលដៅសម្រេចឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ថវិកាអាចបំពេញមុខងារជាឧបករណ៍ដ៏ស័ក្តិសិទ្ធិរបស់គោលនយោបាយបាន លុះត្រាតែលក្ខណៈសម្បត្តិទាំង៤ប្រការ ដូចខាងក្រោម ត្រូវបានបំពេញ គឺ÷

ទី១. ប្រព័ន្ធ ត្រូវបានរៀបចំត្រឹមត្រូវ÷ បានន័យថា រចនាសម្ព័ន្ធគោលនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រង ត្រូវបានកំណត់ជាក់លាក់ ទាំងកត្តាទំនាក់ទំនងផ្សារភ្ជាប់ ទាំងកត្តាលំដាប់ថ្នាក់នានុក្រម។

ទី២. យន្តការ ត្រូវបានកំណត់ច្បាស់លាស់÷ មានន័យថា រចនាសម្ព័ន្ធគោលនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រង អាចដំណើរការទៅដោយប្រទាក់ក្រឡាគ្នាបាន លុះត្រាតែវិធាន នីតិវិធី មុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់គ្រប់តួអង្គពាក់ព័ន្ធ ជាអាទិ៍ អង្គភាពហិរញ្ញវត្ថុ អង្គភាពថវិកា ត្រូវបានកំណត់ឱ្យមានជាខ្សែបន្ទាត់គណនេយ្យភាពជាក់លាក់។

ទី៣. ក្របខ័ណ្ឌគតិយុត្ត ត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្ត÷ ក្នុងន័យនេះ ប្រព័ន្ធ និងយន្តការ ដែលបានកំណត់ខាងលើត្រូវរៀបចំឡើងនៅក្នុងក្របខ័ណ្ឌគតិយុត្តមួយ ប្រកបដោយនីត្យានុកូលភាព (*ស្របច្បាប់*) និងគតិយុត្តភាព (*ត្រឹមត្រូវតាមវិធីសាស្ត្រច្បាប់ មានការគោរពឋានានុក្រមគតិយុត្ត អានុភាពគតិយុត្ត សមស្របតាមកម្លាំងគតិយុត្តនៃលិខិតបទដ្ឋានដែលបានដាក់ចេញជាដើម*)។

ទី៤. ធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យ÷ បានសេចក្តីថា ធនធានមនុស្សត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីធានានិច្ចដំណើរការប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

មុននឹងបញ្ចប់ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខ្ញុំសូមសម្តែងកតញ្ញូកតវេទិតាធម៌ដោយគារវកិច្ចយ៉ាងវិសុទ្ធ ជូនចំពោះ អគ្គមហាបុរសនៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់ចក្ខុវិស័យដឹកនាំដ៏ប្រាកដនិយម និងស្ថាបនាមាគ៌ានយោបាយដ៏ត្រឹមត្រូវ ដើម្បីសម្រេចជោគជ័យលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅ ជូនចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែបានផ្តល់ឱវាទដឹកនាំដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ក្នុងនាមជាសសរស្តម្ភមួយ នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ្ញុំសូមសម្តែងមូលវិចារដ៏ថ្លៃវិសេសជូនដល់សម្តេច ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន ដែលតែងតែដឹកនាំ និងគាំទ្រដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបាន និងកំពុងចូលរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស្មារតី និងសតិសម្បជញ្ញៈ នៃភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងភាពជាអ្នកដឹកនាំគម្រូលើការងារកែទម្រង់ រហូតសម្រេចបានសមិទ្ធផលដ៏វិសេសនាពេលនេះ។

ជាចុងក្រោយ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈកិច្ចសហការ និងកិច្ចសម្របសម្រួលជាប្រចាំជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ្ញុំរំពឹងថា ចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” នេះ នឹងក្លាយជាប្រទីបគោចរបង្ហាញផ្លូវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ អំពីកិច្ចដំណើរការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព៕ ■

រាជធានីភ្នំពេញ ថ្ងៃទី១៩ខែមករាឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់អាទិភាពមួយដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលដៅកែប្រែប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានរយៈពេលវែង និងគោលដៅយុទ្ធសាស្ត្រច្បាស់លាស់ ដោយបានកំណត់ និងចែកចេញជា ៤ជំហាន និង៤ដំណាក់កាល ដូចជា ភាពជឿទុកចិត្តបាននៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, និងគណនេយ្យភាពចំពោះសមិទ្ធកម្ម។

រហូតដល់ឆ្នាំ ២០១៦ តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលគន្លឹះជាច្រើន ដូចជាការផ្លាស់ប្តូរពីស្ថានភាពកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាអតិរេកសាច់ប្រាក់ ការលុបបំបាត់បាននូវបំណុលកកស្ទះ និងការបង្កើតបាននូវអង្គភាពសវនកម្មផ្ទៃក្នុងតាមក្រសួង- ស្ថាប័ន ជាដើម ដែលជាមូលដ្ឋានក្នុង ឆ្លងកាត់នូវដំណាក់កាលទី១ នៃ **ភាពជឿទុកចិត្តនៃថវិកា** និងបោះជំហានទៅកាន់ដំណាក់កាលទី២ នៃ **គណនេយ្យភាពហិរញ្ញវត្ថុ** ដែលឈានទៅរកការសម្រេចថ្មី ផ្សេងទៀតដូចជា ការកែលម្អលើនីតិវិធីអនុវត្តថវិកា មាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ព្រមទាំងការដាក់ឱ្យអនុវត្តនូវគម្រោងប្រព័ន្ធព័ត៌មាន វិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី១។ ទន្ទឹមនេះ ឆ្នាំ២០១៦ គឺជាការបើកទំព័រថ្មីមួយទៀត សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈ ក្នុងការសម្រេចបាននូវដំណាក់កាលទី២ នឹងចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ នៃ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**។ ក្រៅពីសមិទ្ធផលគន្លឹះនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលជាសមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏បានបង្កើត, ប្រមូលផ្តុំ, ចងក្រងនូវឯកសារ, អនុសាសន៍របស់ថ្នាក់ដឹកនាំ បទពិសោធន៍ និងគំនិតថ្មីជាច្រើន ពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ការចូលរួមកែលម្អរបស់តួអង្គពាក់ព័ន្ធ និងបានរំលេចចេញតាមរយៈសំណេរអត្ថបទក្នុងព្រឹត្តបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈជាប្រចាំឆ្នាំ។

តាមរយៈព្រឹត្តបត្រនេះ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងសាធារណៈជាតិ និងអន្តរជាតិ ក៏នឹងទទួលបាននូវព័ត៌មានបន្ថែម ព្រមទាំងអាចចូលរួមចំណែកតាមរយៈការចូលរួមសំណេរអត្ថបទពាក់ព័ន្ធនានា ដែលអាចផ្តល់នូវឧត្តមប្រយោជន៍ជូនសង្គមជាតិខ្មែរ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍជាតិ។

ក្រោមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល ក៏ដូចជាការដឹកនាំផ្ទាល់របស់ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានខិតខំលើកកម្ពស់ការយល់ដឹងអំពីសារៈប្រយោជន៍នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយទន្ទឹមនេះ អគ្គលេខាធិការដ្ឋាន ក៏សូមចូលរួមចំណែកវាយតម្លៃខ្ពស់ជូនចំពោះគ្រប់តួអង្គពាក់ព័ន្ធដែលចូលរួមជាសំណេរអត្ថបទ និងការចូលរួមក្រោមរូបភាពផ្សេងៗទៀត ដែលក្នុងគោលដៅតម្កល់ប្រយោជន៍ជាតិជាធំ៕ ■

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា


០១ ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

០៣ ការវិភាជថវិកាឆ្នាំ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ជាតិ

០៥ ទស្សនាទាននៃការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

០៧ សារាចរ ស្ដីពី វិធាននិងនីតិវិធីនៃការរៀបចំការអនុវត្តការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៣ ការពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

១៥ ការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងការវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៧ បទពិសោធន៍ ស្ដីពីកំណែទម្រង់ប្រព័ន្ធគោលនយោបាយនិងរដ្ឋបាលពន្ធរបស់ព្រះរាជាណាចក្រថៃ

២៣ តើមានអ្វីប្លែក ក្នុងក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ឆ្នាំ២០១៦?

២៦ រដ្ឋបាលថ្នាក់ក្រោមជាតិ នៅប្រទេសកម្ពុជា

៣១ វិធីសាស្ត្រដាក់ពិន្ទុសម្រាប់វាយតម្លៃផែនការសកម្មភាព ដំណាក់កាលទី៣

៣៣ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

៣៦ បទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា

៤០ សារៈប្រយោជន៍នៃកម្ម-វិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមកលើអភិបាលកិច្ចល្អ

# ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

ច្បាប់ទូទាត់ថវិកាឆ្នាំ២០១៤ គឺជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុត ដើម្បីអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** សំដៅឈានទៅសម្រេចឱ្យបាននូវរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៤**

ទន្ទឹមនេះ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ហើយសេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដោយគោរពទាំងស្រុង ទាំងកាលវសាន ទាំងខ្លឹមសារនៃមាត្រា៧៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើការបូកសរុបទិន្នន័យចំណូល និងចំណាយថវិកាដែលត្រូវបានកត់ត្រាដោយគណនេយ្យករសាធារណៈ និងការផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃទិន្នន័យទាំងនេះជាមួយអាណាប័កពាក់ព័ន្ធ ទាំងក្នុងកម្រិតថវិកាថ្នាក់ជាតិ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាលទ្ធផល សេចក្តីព្រាងច្បាប់នេះ បានបង្ហាញពីការសម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗក្នុងការអនុវត្តគោលនយោបាយនិងវិធានការពាក់ព័ន្ធនានារបស់រដ្ឋាភិបាលក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌថវិកាឆ្នាំ២០១៤ ផងដែរ។

ដោយឡែក ការទូទាត់ថវិកា ត្រូវធ្វើជារៀងរាល់ឆ្នាំ និងជាកម្មវត្ថុនៃច្បាប់។ សេចក្តីព្រាងច្បាប់ទូទាត់ថវិកា នឹងបង្ហាញ ពីការកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូលដែលបានបង់ចូលគណនីទោលរបស់រតនាគារជាតិ និងអាណាប័ណ្ណចំណាយ ដែលបានប្រព្រឹត្តនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។ សេចក្តីព្រាងច្បាប់នេះ បង្ហាញឱ្យឃើញនូវលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដោយធ្វើការកត់ត្រាទៅក្នុង "គណនីលទ្ធផល" របស់រតនាគារជាតិ តែសម្រាប់ឥណទានដែលមិនបានប្រើប្រាស់នឹងត្រូវចាត់ទុកជាមោឃៈ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមមាតិកាថវិកានីមួយៗ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាង
ច្បាប់
ស្តីពី
ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់
ការគ្រប់គ្រងឆ្នាំ២០១៤

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥

ដោយផ្អែកលើទិន្នន័យចំណូលចំណាយ រាយការណ៍ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករ សាធារណៈ និងផ្ទៀងផ្ទាត់អំពីសុក្រឹតភាពទិន្នន័យទាំងនេះដោយអាណាប័ក ទាំងសម្រាប់ថវិកាថ្នាក់ជាតិនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យនិងសម្រេចដាក់ជូនសភា ពិភាក្សានិងអនុម័ត។

របាយការណ៍នៃការអនុវត្តថវិកានេះ ចាំបាច់ត្រូវបង្ហាញនូវកិច្ចប្រតិបត្តិការនានា ដែលរួមមានដូចតទៅ÷

១. របាយការណ៍ចំណូល-ចំណាយថវិកាថ្នាក់ជាតិនៃកិច្ចប្រតិបត្តិការទូទៅ

២. របាយការណ៍កិច្ចប្រតិបត្តិការចំណូល-ចំណាយ ដែលអនុវត្តឆ្លងកាត់រតនាគារជាតិ

៣. របាយការណ៍កិច្ចប្រតិបត្តិការចំណូល-ចំណាយ ដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិ

៤. របាយការណ៍តុល្យភាពហិរញ្ញវត្ថុសាធារណៈ

៥. របាយការណ៍ចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី-ខេត្ត និង

៦. របាយការណ៍ចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិរដ្ឋបាលក្រុង-ស្រុក។

ក្នុងកិច្ចដំណើរការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកានេះ ការតាមដានត្រួតពិនិត្យលើការអនុវត្តថវិកា បានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយ ទិសដៅដែលត្រូវបន្តអនុវត្ត និងវិធានការដែលត្រូវប្រកាន់យកដើម្បីអនុវត្តថវិកានៃឆ្នាំបន្ទាប់។



ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ បានបង្ហាញថាក្នុងឆ្នាំ២០១៤ ចំណូលថវិកាអនុវត្តបានចំនួន១៥.២៧០.៩៤០,៨លានរៀល រីឯចំណាយថវិកាអនុវត្តបានចំនួន ១៤.០៦៧.៩៣២,០ លានរៀល ដែលនាំឱ្យលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៤ មានអតិរេក (Surplus) ចំនួន ១.២០៣.០០៨,៨ លានរៀល។ សម្រាប់ចំណូលចរន្ត និងចំណាយចរន្ត មានអតិរេកចំនួន ១.៤២៣.៣៥៤,៧ លានរៀល រីឯសម្រាប់ចំណូលមូលធន និងចំណាយមូលធន មានឱនភាពចំនួន ១.១៥៣.២០៤ លានរៀល។

សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលបានអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៤ បានតាមអាទិភាពគោលនយោបាយសំខាន់ៗរបស់ខ្លួន ដែលជាសូចនាករសំខាន់ៗ នៃម៉ាក្រូសេដ្ឋកិច្ច ដូចជា កំណើនសេដ្ឋកិច្ចសម្រេចបាន ៧.១% នៃ ផសសធៀបនឹងការគ្រោងទុក (ប្រមាណ ៧% នៃ ផសស) ផសសសម្រាប់មនុស្សម្នាក់ៗ សម្រេចបាន ១.១៣៨ ដុល្លារអាមេរិក អតិផរណារក្សាបាន ៣.៩% ធៀបនឹងការគ្រោងទុក (គឺក្នុងរង្វង់ ៣.៥%) អត្រាប្តូរប្រាក់ សម្រេចបានជាមធ្យម ៤.០៣៩រៀល ក្នុងមួយដុល្លារអាមេរិក ធៀបនឹងការគ្រោងទុក (៤.០៥០រៀល ក្នុងមួយដុល្លារអាមេរិក) និងការអនុវត្តចំណូលសរុបសម្រេចបាន ១,៨៤% នៃផសស ធៀបនឹងការគ្រោងទុក (០,៥០% នៃផសស) ដែលជាលទ្ធផលនាំឱ្យមានលទ្ធភាពសន្សំ ។

**ចំណូលចរន្ត និងចំណាយចរន្ត មានអតិរេកចំនួន ១.៤២៣.៣៥៤,៧ លានរៀល រីឯ សម្រាប់ចំណូលមូលធន និងចំណាយមូលធន មានឱនភាពចំនួន ១.១៥៣.២០៤ លានរៀល។**

ផ្អែកលើមូលដ្ឋាននៃការសម្រេចបាននូវសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបាននិងកំពុងអនុវត្តជាបណ្តើរៗ ក្នុងដំណាក់កាលទី៣នេះ រាជរដ្ឋាភិបាលកាន់តែមានសុទិដ្ឋិនិយមថា កម្ពុជាពិតជាបាន និងកំពុងដើរលើផ្លូវដ៏ត្រឹមត្រូវ ដើម្បីអាចក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ខាងមុខ ជាក់ជាមិនខាន។

# ការវិភាជថវិកាឆ្នាំ ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ជាតិ

## ការរៀបចំច្បាប់ថវិកាឆ្នាំ២០១៦ ត្រូវបានធ្វើឡើងដោយឈរលើគោលការណ៍គន្លឹះៗរួមមាន ការកំណត់អាទិភាព ដែលសំដៅដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជទៅតាមវិស័យអាទិភាពស្របតាមគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល

ការយកចិត្តទុកដាក់លើធនធានមនុស្ស ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារ, ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្តដើម្បីធានាប្រសិទ្ធភាពចំណាយ និងការគ្រប់គ្រងចាត់ចែងការអនុវត្តថវិកា ប្រកបដោយភាពទាន់ពេលវេលា និងការទទួលខុសត្រូវច្បាស់លាស់, ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាពទាំងថ្លៃបរិមាណ និងគុណភាព ដើម្បីកាត់បន្ថយភាពខ្វះខាតក្នុងការអនុវត្ត, និងការផ្សារភ្ជាប់រវាងការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការវិភាជថវិកាដែលសំដៅដល់ការវិភាជថវិកាត្រូវផ្សារភ្ជាប់ទៅនឹងលទ្ធផលនៃការអនុវត្តចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

លើសពីនេះ ការវិភាជថវិកាឆ្នាំ២០១៦ ត្រូវបានផ្តោតការយកចិត្តទុកដាក់លើការតម្លើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, បង្កើនចំណាយលើវិស័យអប់រំ ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ វិស័យសុខាភិបាល, វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ដែលជាមូលដ្ឋានគ្រឹះនៃការជំរុញ កំណើន និងការប្រកួតប្រជែងរបស់កម្ពុជា។



សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ចំណូលថ្នាក់ជាតិសរុបត្រូវបានគ្រោងចំនួន ១៧ ៦១២ ៤៧៧ លានរៀល ស្មើនឹង ២១,៥% នៃផ.ស.ស ក្នុងនោះចំណូលចរន្តថ្នាក់ជាតិ គ្រោងទឹកប្រាក់សរុបចំនួន ១៣ ៤០៧ ២៦៣ លានរៀល ស្មើនឹង ១៦,៣៦% នៃផ.ស.ស. ឬកើន២១,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៥ និងចំណូលមូលធនថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ៤ ២០៥ ២១៤ លានរៀល ស្មើនឹង ៥,១៣% នៃផ.ស.ស ឬកើន ២,១% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

ដោយឡែក ចំណាយថវិកាថ្នាក់ជាតិសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវបានគ្រោងក្នុងទឹកប្រាក់ ១៧ ៤៦២ ៤៧៧ លានរៀល ស្មើនឹង ២១,៣១% នៃ ផ.ស.ស. ឬកើន ១៦,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ក្នុងនោះចំណាយចរន្តថវិកាថ្នាក់ជាតិមានទឹកប្រាក់សរុប ១១ ១៥៦ ៩៨៩ លានរៀល ដែលមានសមាមាត្រស្មើនឹង៦៣,៩% នៃចំណាយថវិកាថ្នាក់ជាតិសរុប ឬស្មើនឹង ១៣,៦២% នៃ ផ.ស.ស ឬកើន ២០,៣% នៃច្បាប់ឆ្នាំ២០១៥ និងចំណាយមូលធនមានទឹកប្រាក់សរុប ៦ ៣០៥ ៤៨៨ លានរៀល ដែលមានសមាមាត្រស្មើនឹង ៣៦,១% នៃចំណាយថវិកាថ្នាក់ជាតិសរុប ឬ ស្មើនឹង ២,៣៥% នៃផ.ស.ស ឬកើន ៩,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

ចំណាយថវិកាថ្នាក់ជាតិសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវបានគ្រោងក្នុងទឹកប្រាក់ ១៧ ៤៦២ ៤៧៧ លានរៀល ស្មើនឹង ២១,៣១% នៃ ផ.ស.ស. ឬកើន ១៦,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

សម្រាប់ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជសម្រាប់ចំណាយបន្ទុកបុគ្គលិក (ដោយផ្តោតអាទិភាពលើការតម្លើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២% និងប្រាក់បំណាច់មុខងារ) និងក្រៅបន្ទុកបុគ្គលិកដូចខាងក្រោម÷

| | ភាគរយធៀបនឹងចំណាយចរន្តថវិកាថ្នាក់ជាតិសរុប | ភាគរយធៀបនឹងផ.ស.ស. | កំណើនធៀបច្បាប់ឆ្នាំ២០១៥ |
|---|---|---|---|
| ចំណាយបន្ទុកបុគ្គលិក | ៥០,៥២% | ៦,៨៨% | ២៣,៤% |
| ចំណាយក្រៅបន្ទុកបុគ្គលិក | ៤៩,៤៨% | ៦,៧៤% | ១៧,២% |

ការវិភាជចំណាយចរន្តថវិកាថ្នាក់ជាតិទៅតាមវិស័យ ក៏ត្រូវបានធ្វើឡើងដូចខាងក្រោម÷

| | ភាគរយធៀបនឹងចំណាយចរន្តថវិកាថ្នាក់ជាតិសរុប | (%)ភាគរយធៀបនឹងផ.ស.ស. | កំណើនធៀបច្បាប់ឆ្នាំ២០១៥ |
|---|---|---|---|
| វិស័យសង្គមកិច្ច | ៣៨,៥% | ៥,២៤% | ១៩,៧% |
| វិស័យសេដ្ឋកិច្ច | ១០,៣៥% | ១,៤១% | ១៦,១% |
| វិស័យរដ្ឋបាលទូទៅ | ១៤,៣២% | ១,៩៥% | ២១,០% |
| វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២៤,៨៥% | ៣,៣៨% | ១៩,៧% |

ជារួម សម្រាប់តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ មានអតិរេកនៃថវិកាចរន្តចំនួន ២ ២៥០ ២៧៤ លានរៀល ឬឱនភាពសរុបធៀបនឹងថវិកាថ្នាក់ជាតិ មានប្រមាណ ៣ ៤១៥ ២១២ លានរៀល។ ដោយឡែកសម្រាប់ហិរញ្ញប្បទាននៃឱនភាព មានទំហំ ៣ ៤១៥ ២១២ លានរៀល។ ■

# ទស្សនាទាននៃការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

**ទស្សនាទាននៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (ក.ច.រ.ម "MTEF") កើតមានចាប់តាំងពីទសវត្សរ៍ទី៨០ ក្នុងប្រទេសនៃទ្វីបអឺរ៉ុប និងទ្វីបអូសេអានី ជាបន្តបន្ទាប់។ ប៉ុន្តែក្នុងកំឡុងទសវត្សរ៍ទី៩០ ទស្សនាទាននេះ ត្រូវបានយល់ និងប្រើប្រាស់ក្នុងទិដ្ឋភាព ២ផ្សេងគ្នា សម្រាប់ក្រុមប្រទេសមានចំណូលមធ្យម ឬទាប និងក្រុមប្រទេសមានចំណូលខ្ពស់។**

ការប្រើប្រាស់ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ក្នុងការធានាភាពគ្រប់គ្រាន់នៃធនធានសម្រាប់បម្រើគោលនយោបាយអាទិភាពដោយរួមទាំងការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលមធ្យមពីដៃគូអភិវឌ្ឍន៍នានាដែលជាម្ចាស់ជំនួយសម្រាប់ប្រទេសមានចំណូលមធ្យមឬទាប។ ដោយឡែកសម្រាប់ប្រទេសមានចំណូលខ្ពស់ ការប្រើប្រាស់ ក.ច.រ.ម. ដើម្បីសម្រេចបាននូវគោលដៅចំណូលចំណាយដែលបានដាក់ចេញ, លើកកម្ពស់អាទិភាពគោលនយោបាយ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។ ក.ច.រ.ម ក៏ជាឧបករណ៍ព្យាករណ៍បន្ថែម ដែលពន្លាតពីការរៀបចំថវិការយៈពេលមួយឆ្នាំ ទៅរយៈពេល៣ ឬ៤ ឆ្នាំ។

កម្មវត្ថុនៃការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម រួមមាន (១)កែលម្អស្ថានភាពម៉ាក្រូសារពើពន្ធ សំដៅកាត់បន្ថយឱនភាពថវិកា និងបង្កើនកំណើនសេដ្ឋកិច្ច ព្រមទាំងនិរន្តរភាពសេដ្ឋកិច្ច (២)បង្កើនប្រសិទ្ធភាពនៃគោលនយោបាយរបស់ រដ្ឋាភិបាល សំដៅបង្កើនប្រសិទ្ធភាពនៃការវិភាជចំគោលដៅតាមអាទិភាពគោលនយោបាយយុទ្ធសាស្ត្រជាតិ, (៣)ធានាបាននូវប្រសិទ្ធភាព និងសង្គតិភាពលើការព្យាករណ៍នៃគោលនយោបាយ និងធនធាន, និង (៤)កែលម្អសមិទ្ធកម្មតាមកម្មវិធី និងវិបាកនៃការអនុវត្ត សំដៅដល់ការកាត់បន្ថយនូវការិយាធិបតេយ្យដោយបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្កើនភាពបត់បែនក្នុងការគ្រប់គ្រង និងនវានុវត្តនៃការអនុវត្តការងារ។

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម គឺជាការផ្សារភ្ជាប់រវាងគោលនយោបាយ, ផែនការ និងថវិកា ក្នុងរយៈពេលមធ្យម ដែលមាន ២ អភិក្រម គឺ (១)អភិក្រមពីលើចុះក្រោម មានទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយជាតិ, និង (២) ពីក្រោមឡើងលើ ឆ្លុះបញ្ចាំងពីការព្យាករណ៍លើប្រភពធនធានសម្រាប់ការអនុវត្តដែលអាចបង្កើនប្រសិទ្ធភាពនៃការសម្រេចចិត្តស្របជាមួយនឹងធនធានដែលមាន។

> ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមពេញលេញ នឹងផ្តល់នូវសារៈប្រយោជន៍ជាច្រើនសម្រាប់ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសមួយ

- **អភិក្រមពីលើចុះក្រោម** គឺជាការពិនិត្យលើម៉ាក្រូសេដ្ឋកិច្ចដែលមានឥទ្ធិពលដល់ការព្យាករណ៍ចំណូល និងចំណាយរបស់រដ្ឋាភិបាល។ ម្យ៉ាងទៀត ការរៀបចំនេះ គឺផ្តោតទៅលើការព្យាករណ៍សម្រាប់រយៈពេលមធ្យមនៃលទ្ធភាពនៃការប្រមូលចំណូល (ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ) របស់អង្គភាពប្រមូលចំណូល, យុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងហិរញ្ញប្បទានពីប្រភពផ្សេងៗ ដែលជាប្រភពនៃចំណូល ដោយឡែក និងកំណត់ប្រភពចំណូលផ្សេងៗ ទៀត ជាដើម ព្រមទាំងការព្យាករណ៍នៃចំណាយសាធារណៈ។
- **អភិក្រមពីក្រោមឡើងលើ** ដែលផ្តោតការព្យាករណ៍សម្រាប់រយៈពេលមធ្យមលើតម្រូវការថវិកាដែលត្រូវគ្រោងដោយអង្គភាពចំណាយ (អង្គភាពថវិកា)។ ក្រសួងហិរញ្ញវត្ថុ ឬស្ថាប័នដែលទទួលបន្ទុក ត្រូវរៀបចំគោលការណ៍ណែនាំក្នុងការរៀបចំថវិកា ដែលជាសារាចរស្តីពីការរៀបចំថវិការយៈពេលមធ្យម ដែលរំលេចទាំងផែនការយុទ្ធសាស្ត្រជាតិរយៈពេលមធ្យម, យុទ្ធសាស្ត្រអាទិភាពរបស់រដ្ឋាភិបាលរយៈពេលមធ្យម, ពិដានថវិកាដែលត្រូវដាក់ចេញសម្រាប់ខ្ទង់ចំណាយនីមួយៗ ព្រមទាំងតម្លៃឯកតាចំណាយដែលមានលក្ខណៈស្តង់ដាររួម ជាដើម ដើម្បីធ្វើជាមូលដ្ឋានសម្រាប់អង្គភាពចំណាយ (អង្គភាពថវិកា) ក្នុងការគ្រោងតម្រូវការ

ចរិការយៈពេលមធ្យមប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីអាចធានាបានប្រសិទ្ធភាពនៃការវិភាជថវិកា។ ទន្ទឹមនេះ ការរៀបចំតាមបែបអភិក្រមពីក្រោមឡើងលើ គឺត្រូវមានសង្គតិភាព




និងសមានគតិភាពជាមួយនឹងការរៀបចំតាមបែបពីលើចុះក្រោមដែលមានកំណត់ក្នុងការរៀបចំក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យមខាងលើ) ដើម្បីឆ្លុះបញ្ចាំងនូវភាពគ្រប់គ្រាន់នៃធនធានទៅនឹងអាទិភាពនៃតម្រូវការថវិការបស់អង្គភាពចំណាយ (អង្គភាពថវិកា)។ តម្រូវការថវិការយៈពេលមធ្យម នឹងត្រូវបានអនុម័តបន្ទាប់ពីការកែសម្រួលនិងព្រមព្រៀង។ លើសពីនេះតម្រូវការថវិការយៈពេលមធ្យម ក៏អាចត្រូវបានផ្សព្វផ្សាយជាសាធារណៈផងដែរ។

- **គោលដៅសូចនាករសមិទ្ធកម្ម** ក៏ត្រូវបានកំណត់ក្នុងផែនការសកម្មភាពរយៈពេលមធ្យមតាមគោលបំណង គោលនយោបាយ កម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ជាដើម។ អង្គភាពចំណាយ (អង្គភាពថវិកា) ត្រូវរៀបចំគោលដៅសូចនាករដោយផ្សារភ្ជាប់ថវិកាទៅនឹងគោលដៅអាទិភាព ហើយការរៀបចំនេះនឹងធ្វើជាមូលដ្ឋានក្នុងការរាយការណ៍ទៅតាមគោលដៅសូចនាករដែលបានដាក់ចេញ និងអនុម័ត។

ដូចនេះ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម មានប្រសិទ្ធភាពលុះត្រាតែក្របខ័ណ្ឌនេះត្រូវបានប្រើប្រាស់ក្នុងការសម្រេចចិត្តក្នុងដំណើរការ ឬវដ្តថវិកា។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមពេញលេញនឹងផ្តល់នូវសារៈប្រយោជន៍ជាច្រើនសម្រាប់ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសមួយដូចជា ផ្តល់នូវព័ត៌មានថវិកាគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើវដ្តនៃថវិកាពេញលេញ, បង្កើនប្រសិទ្ធភាពព្យាករណ៍ក្នុងរយៈពេលមធ្យមដែលផ្តល់ដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុជាមួយនឹងអាទិភាពគោលនយោបាយរបស់ខ្លួន, ធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, ប្រសិទ្ធភាពលើការធ្វើប្រតិភូកម្មអំណាចសម្រាប់អង្គភាពថវិកា និងមូលដ្ឋាននៃការធ្វើផែនការថវិការយៈពេលមធ្យមដ៏រឹងមាំប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការឈានទៅរៀបចំ និងអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម តម្រូវឱ្យប្រទេសនីមួយៗ ត្រៀមជាស្រេចនូវការរៀបចំ ពង្រឹង ឬកែលម្អលើចំនុចដូចជា÷

- ភាពទុកចិត្តបាននៃប្រព័ន្ធថវិកាដែលផ្តោតជាសំខាន់លើគម្លាតនៃការព្យាករណ៍ថវិកា និងការអនុវត្តថវិកាជាក់ស្តែងមិនមានកម្រិតលម្អៀងខ្លាំង
- សមត្ថភាពនៃការរៀបចំ និងព្យាករណ៍នូវទិន្នន័យឬស្ថិតិសេដ្ឋកិច្ចដែលអាចទុកចិត្តបាន ដែលមានសារៈសំខាន់ និងជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច
- សមត្ថភាពនៃការព្យាករណ៍ ឬកំណត់រកនូវកម្រិតហានិភ័យពាក់ព័ន្ធថវិកាសម្រាប់គោលនយោបាយដែលបានអនុម័ត
- ស្ថេរភាពសារពើពន្ធ ដែលជាមូលដ្ឋានដ៏ចម្បងសម្រាប់ធ្វើការសម្រេចចិត្តសម្រាប់រយៈពេលមធ្យម
- ។ល។ ■




# សារាចរស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាននិងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាជាជំហានៗឆ្ពោះទៅរកស្តង់ដារអន្តរជាតិ នោះគឺ ការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ (២០១៣-២០២០)

តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេលវែង គ្រប់ជ្រុងជ្រោយ និងអនុវត្តយុទ្ធសាស្រ្ត ៤ជំហាន ឬ/និង ៤ដំណាក់កាលគឺ (១)ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ(៣)ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤) ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម។ ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាំបាច់ត្រូវមានការរៀបចំ និងអនុវត្តផែនការសកម្មភាពរួម ដែលអនុម័ត និងដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលតាមសំណើរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា




"**គ.ហ.ស.**" និងតម្រូវឱ្យក្រសួង-ស្ថាប័ននីមួយៗ រៀបចំ និងអនុវត្តផែនការសកម្មភាពលម្អិតរបស់ខ្លួនដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល តែត្រូវមានសង្គតិភាព និងបូរណភាពជាមួយនឹងផែនការសកម្មភាពរួម។

អនុលោមតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធត្រូវរៀបចំបង្កើត "ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" មួយដែលហៅកាត់ថា"**គ.ហ.ស**" នៅក្នុងក្រសួង-ស្ថាប័ន និងអង្គភាពរបស់ខ្លួន។ ទន្ទឹមនឹងនេះ ដើម្បីធានាសង្គតិភាព និងសមានគតិភាពនៃការរៀបចំ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ ព្រមទាំងសុក្រឹតភាព និងភាពទាន់ពេលនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចរៀបចំ និងដាក់ឱ្យអនុវត្ត "**សារាចរស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" នៅគ្រប់ក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធ្វើការកំណត់និងដាក់ចេញនូវយន្តការ វិធាន និងនីតិវិធី ដូចតទៅ÷

## ក. យន្តការស្ថាប័ន

**គ.ហ.ស.** ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង-ស្ថាប័ន ០១ រូប ជា **គ.ហ.ស.** និងជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬ ថ្នាក់ដឹកនាំមួយរូបដែលទទួលបន្ទុកជួយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុ របស់ក្រសួង-ស្ថាប័ន។ ទន្ទឹមនេះ ក៏តម្រូវឱ្យចាត់តាំងអនុប្រធាន ០១រូប ផងដែរ ដែលជាអនុរដ្ឋលេខាធិការ ឬ អគ្គលេខាធិការ ឬ អគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ ឬ ថ្នាក់ដឹកនាំដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **គ.ហ.ស.**។ ក្នុងនោះ សមាជិកនៃ **គ.ហ.ស.** ត្រូវមានតំណាង ០១ រូប ពីគ្រប់អគ្គនាយកដ្ឋាន ឬ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង-ស្ថាប័នផ្ទាល់ និងតំណាង ០១ រូប នៃគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង-ស្ថាប័នសាមី នីមួយៗ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន នីមួយៗ ក៏ត្រូវចាត់តាំងឱ្យមានលេខាធិការ **គ.ហ.ស.** ០១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោលតែងតាំងដោយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ស្របតាមសំណើ និងលក្ខខណ្ឌយោងការងារ ដែលកំណត់ដោយប្រធាន **គ.ហ.ស.**។

**គ្រោងស្ថាប័ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**



## ខ. វិធាន និងនីតិវិធី នៃការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសកម្មភាពលម្អិត អនុលោមតាមក្របខ័ណ្ឌផែនការសកម្មភាពរួម សម្រាប់ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងនោះ **ក.ហ.ស.** នៅតាមក្រសួង-ស្ថាប័ននីមួយៗ មានភារកិច្ចសម្របសម្រួល និងបូកសរុបផែនការសកម្មភាពពីគ្រប់ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ រួចផ្ញើមក អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។ ជាពិសេស ផែនការសកម្មភាព ត្រូវចុះហត្ថលេខាដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ បន្ទាប់ពីមានការឯកភាពពីប្រធាន **គ.ហ.ស.** និងត្រូវផ្ញើជូនប្រធាន **គ.ហ.ស.** តាមកាលកំណត់។ ដោយឡែក ការរៀបចំផែនការសកម្មភាព របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ក.ហ.ស.** នៃអង្គភាពនីមួយៗ មានភារកិច្ចសម្របសម្រួលលើការរៀបចំ និងបូកសរុបផែនការសកម្មភាពពីគ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដែលការងារនេះត្រូវដឹកនាំផ្ទាល់ដោយប្រធាន **ក.ហ.ស.** ដោយមានមន្ត្រីបង្គោល ឬ ក្រុមមន្ត្រីបង្គោលរបស់ខ្លួនជាសេនាធិការ និងត្រូវផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។ ជាមួយគ្នានេះ ផែនការសកម្មភាពត្រូវចុះហត្ថលេខាទទួលស្គាល់ដោយប្រធានអង្គភាពនីមួយៗ និងត្រូវផ្ញើមក **អ.គ.ហ.** បូកសរុបជាផែនការសកម្មភាពរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងពិភាក្សាក្នុងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬសម្រេចចុះហត្ថលេខា ដាក់ឱ្យអនុវត្តជាផ្លូវការ។

## គ. វិធាន និងនីតិវិធី នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តផែនការសកម្មភាពដែលបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន និងត្រូវសម្រេចឱ្យបាននូវសូចនាករ និងគោលដៅនៃសកម្មភាពនីមួយៗ តាមកាលកំណត់។ ក្នុងនោះ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការតាមដានវឌ្ឍនភាពប្រចាំត្រូវបានដាក់ឱ្យអនុវត្តដូចតទៅ÷

### គ.១. កិច្ចប្រជុំប្រចាំខែ

- ក្រសួង-ស្ថាប័ន÷ **ក.ហ.ស.** នៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែតាមទម្រង់ដែលកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។ ក្នុងករណីចាំបាច់ មន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** អាចត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ **ក.ហ.ស.** នៃអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំប្រចាំខែ ដោយមានការចូលរួមពីមន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែ តាមទម្រង់ដែលកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។
- កិច្ចប្រជុំប្រចាំខែរវាង **អ.គ.ហ.** ជាមួយ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនៅក្នុងសប្តាហ៍ទី២ នៃខែបន្ទាប់ ឬតាមការចាំបាច់ ដើម្បីពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពប្រចាំខែ បញ្ហាប្រឈម និងសំណូមពរ ព្រមទាំងសំណើដំណោះស្រាយជូនប្រធាន **គ.ហ.ស.** ពិនិត្យ និងសម្រេច សម្រាប់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### គ.២. កិច្ចប្រជុំប្រចាំត្រីមាស

វឌ្ឍនភាពការអនុវត្តផែនការសកម្មភាព



កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានតាមដានត្រួតពិនិត្យ ជាប្រចាំត្រីមាស តាមរយៈកិច្ចប្រជុំ ដែលត្រូវរៀបចំក្នុងខែទីមួយ នៃត្រីមាសបន្ទាប់ ឬតាមការចាំបាច់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។ កិច្ចប្រជុំប្រចាំត្រីមាសរួមមានដូចតទៅ÷

- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍន៍។

### គ.៣. កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ

ការអនុវត្តផែនការសកម្មភាព គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវត្រួតពិនិត្យក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលជាកិច្ចប្រជុំត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្រប់ក្រសួង-ស្ថាប័ន។ កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវរៀបចំនៅត្រីមាសទី១ នៃឆ្នាំបន្ទាប់ ឬតាមពេលវេលាជាក់ស្តែង ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។ ទន្ទឹមនេះ ខ្លឹមសារសំខាន់ៗនៃកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវមានការកត់ត្រាក្នុងរបាយការណ៍ និងសេចក្តីសម្រេចសង្ខេបនៃកិច្ចប្រជុំ ដែលត្រូវផ្សព្វផ្សាយជូនគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### គ.៤. យន្តការដោះស្រាយកិច្ចប្រឈម ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់ និងជាការប្រញាប់ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តយន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

## ឃ. វិធាននិងនីតិវិធី នៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃ លើការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



### ឃ.១. ការរៀបចំ និងបូកសរុបរបាយការណ៍សមិទ្ធកម្ម

ចំពោះសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំ និងបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងត្រូវផ្ញើមក **អ.គ.ហ.** តាមកាលបរិច្ឆេទកំណត់ដូចតទៅ÷

- របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស÷ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃត្រីមាសបន្ទាប់។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ÷ យ៉ាងយូរត្រឹមដំណាច់ខែទីមួយ នៃឆ្នាំបន្ទាប់។

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវរៀបចំតាមទម្រង់ដែលកំណត់ដោយប្រធាន **គ.ហ.ស.** តាមសំណើរបស់ **អ.គ.ហ.**។ ជាពិសេស របាយការណ៍សមិទ្ធកម្មដែលត្រូវបានផ្ញើមក **អ.គ.ហ.** ក្រោយកាលបរិច្ឆេទកំណត់ខាងលើ អាចជាកម្មវត្ថុនៃការបដិសេធក្នុងការពិនិត្យ និងបូកសរុបដោយ **អ.គ.ហ.**។



## ឃ.២. ការរៀបចំ និងបូកសរុបរបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម

របាយការណ៍សមិទ្ធកម្មរបស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំ និងបូកសរុបជារបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម ដោយ **អ.គ.ហ.** ដើម្បីដាក់ជូនកិច្ចប្រជុំនៃ **គ.ហ.ស.** ពិនិត្យនិងសម្រេច។

> សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវយកធ្វើជាមូលដ្ឋាននៃការពិចារណាអំពីការផ្ដល់ការលើកទឹកចិត្ត និងការរឹតត្បិត




## ឃ.៣. ការវាយតម្លៃសមិទ្ធកម្ម

ការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ មានគោលដៅវាស់វែងប្រចាំឆ្នាំ អំពីកម្រិតសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




របស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាន និងវិធីសាស្ត្រ នៃការវាយតម្លៃដូចតទៅ÷

- មូលដ្ឋាននៃការវាយតម្លៃមាន ២ គឺ÷
  ១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត
  ២. លទ្ធផលសម្រេចបានធៀបនឹងគោលដៅសូចនាករសមិទ្ធកម្ម។
- វិធីសាស្ត្រនៃការវាយតម្លៃសមិទ្ធកម្មផ្អែកលើការកំណត់ទម្ងន់ជាភាគរយ (%) ដែលមាន ២ កម្រិតដូចតទៅ÷
  ១. កម្រិតផ្អែកគោលបំណង ចង្កោមសកម្មភាពនៃក្របខ័ណ្ឌផែនការសកម្មភាពរួម ត្រូវកំណត់ដោយ **គ.ហ.ស.**។
  ២. កម្រិតសកម្មភាពលម្អិត(កម្រិត ៣ ខ្ទង់) នីមួយៗត្រូវកំណត់ដោយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវពិគ្រោះយោបល់ជា **អ.គ.ហ.**។

មូលដ្ឋាន រូបមន្ត និងវិធីសាស្ត្រនៃការកំណត់ទម្ងន់ និងការវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវសម្រេច និងដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំត្រីមាស នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវផ្សព្វផ្សាយបន្ទាប់ពីមានការសម្រេចក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្សព្វផ្សាយតាមការសម្រេចរបស់ប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេចផ្តល់ចំណាត់ការបន្ត។

## ៦. វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិត

សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវយកធ្វើជាមូលដ្ឋាននៃការពិចារណាអំពីការផ្តល់ការលើកទឹកចិត្ត និងការរឹតត្បិត ដោយគិតគូរបន្ថែមអំពីធនធានមនុស្ស សម្ភារៈ បច្ចេកទេស និងហិរញ្ញវត្ថុដែលត្រូវបានផ្តល់ជូនជាមធ្យោបាយ សម្រាប់អនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិតចែកចេញ ជា ២ កម្រិត ដូចតទៅ÷

- កម្រិតស្ថាប័ន ÷ វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិត អាចអនុវត្តចំពោះឥណទានថវិកាចរន្តក្នុងឆ្នាំដែលកំពុងដំណើរការ ឬចំពោះដំណើរការពិភាក្សា ឬចរចាឥណទានថវិកានៃឆ្នាំបន្ទាប់ សម្រាប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- កម្រិត **គ. ហ. ស.** ÷ វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិត អាចអនុវត្តចំពោះសមាសភាពនៃ **គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអាចជាការផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងគុណបំណាច់ ឬវិធានការរឹតត្បិតនានា តាមវិធាន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិត ជាក់ស្តែងត្រូវដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.** អនុលោមតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។ ■

# ការពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈកម្មវិធីជាតិ ២០១១-២០១៩ បានដាក់ចេញនូវគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

គោលនយោបាយទាំងនេះ ក៏មានកំណត់នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផងដែរ។

ក្នុងឆ្នាំ២០១៧ នេះ ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ កាន់តែត្រូវបានពង្រឹងថែមមួយកម្រិតទៀតតាមរយៈការបង្កើនធនធាន និងការទទួលខុសត្រូវដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សម្រាប់ឆ្នាំ២០១៧ នេះ ថវិកាសរុបប្រមាណ ៤៣៨លានដុល្លារ ដែលក្នុងនោះមានថវិការដ្ឋចំនួនប្រមាណ ៣៩៦លានដុល្លារ និងថវិកាចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ ៤២លានដុល្លារ ត្រូវបានផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ បើប្រៀបធៀបនឹងឆ្នាំ២០១៦ ថវិកានេះមានការកើនឡើងប្រមាណជិត ៧០លានដុល្លារ ដោយសារកំណើនសេដ្ឋកិច្ចជាតិ និងការបង្កើតឱ្យមាននូវប្រភពចំណូលផ្សេងៗទៀតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។




ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំនូវយន្តការថ្មីៗមួយចំនួនថែមទៀត ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្រូបយកធនធានហិរញ្ញវត្ថុបន្ថែម ដែលរួមមាន÷ (១)ការរៀបចំឱ្យមានប្រភពចំណូលផ្ទាល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (២)ការបង្កើតឱ្យមានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និង (៣)ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ។

ក្នុងក្របខ័ណ្ឌនៃមូលនិធិក្រុងស្រុក ដែលបានបង្កើតឡើងរយៈពេល ៤ឆ្នាំកន្លងមកនេះ យើងបានពិនិត្យឃើញពីភាពចាំបាច់ក្នុងការពិនិត្យមើលឡើងវិញអំពីការចំណាយផ្នែករដ្ឋបាល ដើម្បីធានាដល់ការបង្កើនធនធានសម្រាប់ផ្នែកអភិវឌ្ឍន៍ ព្រមទាំងពិនិត្យលទ្ធភាពក្នុងការបង្កើននូវចំនួនភាគរយដ៏សមស្របមួយនៃការវិភាជពីថវិការដ្ឋទៅឱ្យមូលនិធិនេះដើម្បីធានាថា នៅឆ្នាំ២០១៩ រដ្ឋបាលក្រុង ស្រុកនីមួយៗ នឹងមានធនធានឆន្ទានុសិទ្ធិយ៉ាងសមស្រប ក្នុងការបំពេញនូវអាណត្តិរបស់ខ្លួនក្នុងនាមជាតំណាងដែលត្រូវបានប្រជាពលរដ្ឋ បោះឆ្នោតផ្តល់ការទុកចិត្ត។

នៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការចែករំលែកចំណូលពន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានដាក់ឱ្យអនុវត្តឱ្យមានលក្ខណៈទូលំទូលាយជាងមុន ដែលរួមមានការចែករំលែកចំណូលរដ្ឋបាលពន្ធដល់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ដែលកន្លងមកយន្តការនេះត្រូវបានអនុវត្តតែនៅរដ្ឋបាលរាជធានីខេត្តប៉ុណ្ណោះ។

ជាការចាប់ផ្តើម រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការបែងចែកចំណូលពន្ធលើអចលនទ្រព្យរបស់រដ្ឋបាលរាជធានីភ្នំពេញ ៣០% ជូនរដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានីភ្នំពេញ ដែលក្នុងនោះ ១០% ត្រូវបែងចែកជូនរដ្ឋបាលខណ្ឌ និង ២០% ត្រូវបែងចែកជូនរដ្ឋបាល សង្កាត់ ទៅតាមសក្តានុពលនៃការប្រមូលចំណូលពន្ធលើអចលនទ្រព្យនៅតាមភូមិសាស្ត្រសង្កាត់ នីមួយៗ។ ដោយឡែក ពន្ធលើអចលនទ្រព្យរបស់រដ្ឋបាលខេត្ត ត្រូវបែងចែក ៣០% ជូនរដ្ឋបាល សង្កាត់ចំណុះក្រុង ក្នុងដែនរដ្ឋបាលខេត្តនីមួយៗ ទៅតាមសក្តានុពលនៃការប្រមូលចំណូលពន្ធលើអចលនទ្រព្យ នៅតាមភូមិសាស្ត្រសង្កាត់នីមួយៗ។

នៅឆ្នាំ២០១៧នេះដែរ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវយន្តការវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់គម្រោងអភិវឌ្ឍន៍មួយចំនួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមរយៈយន្តការថ្មីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានធនធានបន្ថែមសម្រាប់ការអភិវឌ្ឍ និងអាចពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការរៀបចំ និងអនុវត្តថវិការបស់ខ្លួនថែមទៀតផង។

ទន្ទឹមនេះ យើងក៏កំពុងរៀបចំយន្តការ

> **នៅឆ្នាំ២០១៧នេះដែរ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវយន្តការវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការខិតខំជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធទៅនឹងគោលការណ៍សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមាននូវប្រព័ន្ធបង្វែរថវិកាពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារនានាដែលនឹងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ■



# ការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងការវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភា នេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅក្រសួងចំនួន ១០ ស្របតាមទស្សនាទាននៃទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ឆ្នាំ២០១៣-២០២០ ដែលក្នុងនោះរួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ។

ក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញនាឆ្នាំដំបូងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ.**) បានអនុវត្តស្របតាមគោលការណ៍ណែនាំស្ដីពីការរៀបចំថវិកាកម្មវិធី, គោលការណ៍ណែនាំស្ដីពីការអនុវត្តថវិកាកម្មវិធី និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ដោយសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងនោះរួមមាន ÷ ១-បង្កើតនិងដាក់ឱ្យអនុវត្តអង្គភាពថវិកានៅអង្គភាពក្រោមឱវាទ **កសហវ.** (កម្រិតអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន នៅថ្នាក់កណ្ដាល និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត នៅថ្នាក់មូលដ្ឋាន) និងផ្ដល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកាដែលបានបំពេញគ្រប់លក្ខខណ្ឌតម្រូវជាបន្តបន្ទាប់, ២-សម្រេចបានផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥-២០១៧ ដែលគ្របដណ្ដប់គ្រប់ចំណូលនិងចំណាយ និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ព្រមទាំងការកំណត់សូចនាករ និងការគណនាចំណាយរហូតដល់កម្រិតចង្កោមសកម្មភាព, ៣-រៀបចំនិងចរចាគម្រោងថវិកាប្រចាំឆ្នាំ២ ០១ ៥ ទៅតាមមាតិកាកម្មវិធី (ទៅតាមអនុកម្មវិធី-អង្គភាពថវិកា), និង ៤-ចាប់ផ្ដើមរៀបចំត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា ដែលជាកម្មវត្ថុនៃអត្ថបទនេះ។

ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា តាមទស្សនាទាននៃថវិកាកម្មវិធី រួមមានទាំងការពិនិត្យលើទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន ក្នុងមុខងារជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីសម្រេចពេញមួយជុំនៃវដ្តថវិកា ស្របតាមគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ "របាយការណ៍ស្ដីពីការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងវាយតម្លៃការអនុវត្តថវិកា ប្រចាំឆ្នាំ២០១៥" គឺជាសក្ខីកម្មនៃកិច្ចខិតខំប្រឹងប្រែងរបស់អគ្គលេខាធិការដ្ឋាន ក្នុងនាមជាសេនាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងថវិការបស់ក្រសួង ដែលរបាយការណ៍នេះ ត្រូវបានដាក់ជារបៀបវារៈនៃកិច្ចពិភាក្សាក្នុងកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ២ ០១ ៥ ដែលរៀបចំជាលើកដំបូងក្នុងខែមេសា ឆ្នាំ២០១៦ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដមបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គួរកត់សម្គាល់ផងដែរថា មុននឹងសម្រេចបាននូវរបាយការណ៍ខាងលើក្នុងខែមេសា ឆ្នាំ២០១៦ នេះ អគ្គលេខាធិការដ្ឋាន ដែលមាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុជាសេនាធិការ បានចាប់ផ្ដើមត្រៀមលក្ខណៈក្នុងការត្រួតពិនិត្យ និងវាយតម្លៃ និងបានធ្វើការងារសំខាន់ៗជាច្រើន ជាបន្តបន្ទាប់ ចាប់តាំងពីដើមខែធ្នូ ឆ្នាំ២០១៥ មកម្ល៉េះ។

> ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា តាមទស្សនាទាននៃថវិកាកម្មវិធី រួមមានទាំងការពិនិត្យលើទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម។

ការងារទាំងនោះ រួមមានជាអាទិ៍÷ ១-បង្កើត និងដាក់ចេញឱ្យអនុវត្តនូវទម្រង់សលាកបត្រតាមដានសន្និធិឥណទានតាមអនុគណនី និងតាមចង្កោមសកម្មភាព ដែលអាចឱ្យយើងតាមដានស្ថានភាពសន្និធិធានាចំណាយ, ស្ថានភាពបោះផ្សាយអាណត្តិបើកប្រាក់ និងស្ថានភាពបើកសាច់ប្រាក់ចេញពីរតនាគារជាក់លាក់ ទៅតាមអង្គភាពថវិកានីមួយៗ។ ការកត់ត្រាតាមដានសន្និធិឥណទាន បានផ្ដល់លទ្ធភាពឱ្យអគ្គលេខាធិការដ្ឋាន អាចទទួលបាននូវ




ទិន្នន័យអនុវត្តថវិកាច្បាស់លាស់ និងអាចបូកសរុបបិទបញ្ជីនៃការអនុវត្តថវិការបស់ក្រសួងទាំងមូលបានទាន់ពេលវេលាដើម្បីជាមូលដ្ឋានផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ។ ២-ចាប់ផ្តើមត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពជំនាញរបស់អង្គភាពក្រោមឱវាទក្រសួង ជាលើកដំបូង ដោយធៀបនឹងគោលដៅសូចនាករដែលបានកំណត់ប្រចាំឆ្នាំ ទៅតាមអង្គភាពនីមួយៗ។ ការងារទាំងនេះ តម្រូវឱ្យមានកិច្ចសហការរវាងអគ្គលេខាធិការដ្ឋាន និងអង្គភាពថវិកាជាប្រចាំ តាមរយៈការផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធកម្ម និងកិច្ចប្រជុំផ្ទៀងផ្ទាត់ជាមួយអង្គភាពថវិកាជាច្រើនលើកច្រើនសារ។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះ យើងសម្រេចបាននូវរបាយការណ៍មួយ ដែលបង្ហាញឱ្យឃើញថា ក្នុងការអនុវត្តថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុវត្តចំណូលបាន ១០៩% នៃគោលដៅកំណត់ក្នុងច្បាប់, អនុវត្តចំណាយបាន ៩៧% នៃឥណទានកំណត់ក្នុងច្បាប់ថវិកា និងសម្រេចបានវឌ្ឍនភាពសមិទ្ធកម្មជារួមប្រមាណ ៨៧% នៃគោលដៅសូចនាករ ដែលបានដាក់ចេញ។

ការត្រួតពិនិត្យ និងវាយតម្លៃ បាននាំឱ្យយើងកំណត់បាននូវចំណុចខ្លាំង និងបញ្ហាប្រឈមនានា ទាំងក្នុងការរៀបចំ និងការអនុវត្តថវិកា។ ទោះបីជាការរៀបចំផែនការសកម្មភាពនៅមិនមានសុក្រឹតភាពពេញលេញ ក៏គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានខិតខំបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន និងបានទទួលស្គាល់នូវភាពចាំបាច់នៃការពង្រឹងឆន្ទៈភាពជាម្ចាស់ និងសមត្ថភាពក្នុងការអនុវត្តបរិបទថ្មី ស្របតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រីឯការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ក៏ត្រូវបានធ្វើឡើងប្រកបដោយស្មារតីទទួលខុសត្រូវក្នុងនាមជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ សំដៅទទួលបាននូវរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា ប្រកបដោយគុណភាព និងមានតម្លៃសម្រាប់ជាមូលដ្ឋានកែលម្អការអនុវត្តនាឆ្នាំបន្ទាប់ៗទៀត ស្របតាមអភិក្រម ÷ "រៀនផង ធ្វើផង និងកែលម្អជាបន្តបន្ទាប់" ឈានទៅការផ្លាស់ប្តូរប្រព័ន្ធថវិកាថ្មី។

របាយការណ៍ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនិងវាយតម្លៃការអនុវត្តថវិកានេះ មិនមែនត្រឹមតែជាសមិទ្ធផលរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុតែម្នាក់ឯងនោះទេ ប៉ុន្តែជាសមិទ្ធផលរបស់គ្រប់អង្គភាពថវិកាទាំងអស់ និងជាសមិទ្ធផលរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តថវិកាកម្មវិធីប្រកបដោយភាពជាគំរូ ក្រោមការដឹកនាំដ៏វៃឈ្លាស និងការផ្តល់ទំនុកចិត្តខ្ពស់ពីឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដល់អង្គភាពថវិកា។ លើសពីនេះ របាយការណ៍ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងការវាយតម្លៃថវិកានេះ នឹងក្លាយជាមូលដ្ឋានដ៏មានសារៈសំខាន់ ក្នុងការរៀបចំនិងកែលម្អផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំ នាឆ្នាំខាងមុខ។

ហេតុដូចនេះ ដើម្បីឱ្យការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងការវាយតម្លៃការអនុវត្តថវិកា នាឆ្នាំបន្តបន្ទាប់ទៀត កាន់តែមានសុក្រឹតភាព ប្រសិទ្ធភាព និងគុណភាព គ្រប់អង្គភាពថវិកាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពង្រឹង និងកែលម្អបន្ថែមទាំងការរៀបចំការអនុវត្ត និងការតាមដានការអនុវត្តថវិកាប្រកបដោយភាពជាម្ចាស់ និងបង្កើនកិច្ចសហការ កិច្ចសម្របសម្រួល និងគណនេយ្យភាពនៃការអនុវត្តការងារជំនាញ និងការងារថវិកា សំដៅឈានទៅការប្រើប្រាស់ថវិកាជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ■

# បទពិសោធន៍ ស្ដីពីកំណែទម្រង់ប្រព័ន្ធគោលនយោបាយ និងរដ្ឋបាលពន្ធរបស់ព្រះរាជាណាចក្រថៃ

ដោយសារឥទ្ធិពលកត្តា ០២យ៉ាង គឺ ទី១) កត្តាពីខាងក្រៅក្នុងនោះរួមមាន : ការប្រកួតប្រជែងផ្នែកពន្ធ, កិច្ចសហប្រតិបត្តិការអន្តរជាតិ, អង្គការអន្តរជាតិ, កិច្ចសហប្រតិបត្តិការចម្រុះ ទី២) កត្តាក្នុងស្រុក ក្នុងនោះរួមមាន: ស្ថានភាពសេដ្ឋកិច្ច (វិសមភាព និងការដើរថយក្រោយរបស់ទីផ្សារ), ទំនាក់ទំនងសង្គម និងវប្បធម៌ និងរបបនយោបាយ។

ប្រទេសថៃបានធ្វើការងារកំណែទម្រង់ពន្ធចែកចេញជា ០៤ ដំណាក់កាលរួមមាន÷ ១) ការសិក្សា និងការស៊ើបអង្កេតអំពីបញ្ហា, ហានិភ័យ និងកត្តាដទៃទៀតដែលអាចប៉ះពាល់ដល់ប្រព័ន្ធពន្ធដារ ២) សមត្ថភាពវិភាគនៃការប្រមូលពន្ធ ៣) ការពិនិត្យឡើងវិញ និងបង្កើតគោលនយោបាយពន្ធ ក្នុងលក្ខខណ្ឌរចនាសម្ព័ន្ធពន្ធ និងរដ្ឋបាលសារពើពន្ធ ៤) ការស្នើលទ្ធផលនៃកំណែទម្រង់ពន្ធ (ការកើនឡើងនៃសមាមាត្រ/ផលិតផលក្នុងស្រុកសរុបពន្ធ (GDP Ratio) យ៉ាងហោចណាស់ ៣%) ផ.ស.ស ក្នុងឆ្នាំ ២០១៥ កំណើនប្រទេសថៃ ២.៨% ហើយឆ្នាំ២០១៦ កំណើន ៣.៤%, ការបង្កើនការបង់ពន្ធ តាមចំណាត់ថ្នាក់។ លទ្ធផលសម្រេចបាននៃការងារកែទម្រង់នេះ គឺដើម្បីបង្កើនសមាមាត្រពន្ធក្នុង ផ.ស.ស ឱ្យស្មើ ១៥% ក្នុងឆ្នាំ ២០១៦, ការធ្វើទំនើបកម្ម និងបង្កើនប្រសិទ្ធភាព នៃរចនាសម្ព័ន្ធពន្ធ។

ការងារកែទម្រង់របស់ប្រទេសថៃសម្រាប់ផែនការរយៈពេលវែង ត្រូវផ្អែកលើបរិការណ៍ពិភពលោក និងស្ថានភាពសេដ្ឋកិច្ចដោយកែទម្រង់ពន្ធលើការកាត់បន្ថយសមាមាត្រពន្ធផ្ទាល់, ការបង្កើនសមាមាត្រពន្ធប្រយោល, ប្រព័ន្ធអេឡិចត្រូនិកសម្រាប់ពង្រីកមូលដ្ឋានពន្ធ និងពន្ធ។ បញ្ហាប្រឈមជារឿងធម្មតានៃការងារកែទម្រង់ពន្ធដែលទាមទារភាពជាអ្នកដឹកនាំខ្លាំង, ការទទួលបានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោះស្រាយនិងការធ្វើការងារកែទម្រង់ក្នុងពេលវេលាសមស្រប។ ការងារកែទម្រង់ពន្ធរបស់រដ្ឋាភិបាលមានគោលបំណង ០៤ សំខាន់ៗ ដូចតទៅ÷

- លើកកម្ពស់សមភាពពន្ធ
- បង្កើនការប្រកួតប្រជែងរបស់សហគ្រិនក្នុងស្រុក (លើកទឹកចិត្តផលិតផលក្នុងស្រុក និងអនុគ្រោះពន្ធ)



- សម្រេចបាននូវនិរន្តរភាពសារពើពន្ធរយៈពេលវែង
- ទំនើបកម្មរចនាសម្ព័ន្ធពន្ធដារ, ទំនាក់ទំនងរវាងចំណូលពន្ធជាមួយកំណើនសេដ្ឋកិច្ច និងការបង្កើនប្រសិទ្ធភាពរបស់រដ្ឋបាលសារពើពន្ធ

## ការបែងចែកតួនាទី និងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

### ក. ការិយាល័យគោលនយោបាយត្រូវបានរៀបចំឡើងដោយផ្អែកលើប្រភេទពន្ធរួមមាន÷

- រចនាសម្ព័ន្ធពន្ធ÷ ពន្ធលើប្រាក់ចំណេញ, ពន្ធគយ និងរដ្ឋាករពន្ធដទៃផ្សេងទៀត (ពន្ធលើដី និងអគារ និងពន្ធលើបរិស្ថានជាដើម)។ ការកាត់បន្ថយការជាន់ភារកិច្ចគ្នា និងបញ្ហាការសម្របសម្រួល
- ច្បាប់ប្រព័ន្ធរដ្ឋបាល និងពន្ធ (E-payment និងទូទាត់គណនីហិរញ្ញវត្ថុតែមួយ)

ក្នុងដំណាក់កាលការងារកែទម្រង់គួរឱ្យកត់សម្គាល់ថ្មីៗនេះ គឺ E-payment ដែលអនុញ្ញាតឱ្យអ្នកមានកាតព្វកិច្ចបង់ពន្ធធ្វើការងារទូទាត់ (E-Tax) និងដកប្រាក់តាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រតិបត្តិការរាជរដ្ឋាភិបាល (Government E-Payment) មានភាពងាយស្រួល និងប្រសិទ្ធភាពខ្ពស់។

ដើម្បីធានាឱ្យបាននូវនិរន្តរភាពបំណុលសារពើពន្ធនៅក្រោម ៦០% នៃផលិតផលក្នុងស្រុកសរុប សេវានេះគឺតិចជាង ១៥% នៃថវិការបស់រដ្ឋាភិបាល និងការចំណាយមូលធនច្រើនជាង ២៥% នៃថវិការបស់រដ្ឋាភិបាល (ដើម្បីគាំទ្រដល់កំណើន និងការអភិវឌ្ឍ។ វិន័យសារពើពន្ធរបស់ប្រទេសថៃរួមមានការផ្តល់ហិរញ្ញប្បទាន, ឱនភាពថវិកាជារូបិយវត្ថុក្នុងស្រុក, បង្កើនប្រាក់កម្ចីរូបិយប័ណ្ណមិនលើសពី ១០% នៃថវិកាប្រចាំឆ្នាំ ដោយមានគោលបំណងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការធានាប្រាក់កម្ចី មិនត្រូវលើសពី ២០% នៃថវិកាប្រចាំឆ្នាំនិងថវិកាបន្ថែម។




**ខ. នាយកដ្ឋានចំណូល** ទទួលខុសត្រូវចំពោះការប្រមូលពន្ធ, ស្នើសុំ និងអនុវត្តគោលនយោបាយពន្ធក្នុងគោលបំណងដើម្បីសម្រេចបាននូវគោលដៅតាមរយៈការប្រមូលពន្ធត្រឹមត្រូវ (**សមភាពពន្ធ**) និងដើម្បីឱ្យមានយន្តការក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការប្រកួតប្រជែងរបស់ប្រទេសថៃព្រមទាំងជំរុញឱ្យមានអនុលោមភាពច្បាប់ ពន្ធដោយការស្ម័គ្រចិត្តមួយ។ នាយកដ្ឋានចំណូលប្រមូលពន្ធ ០៦ ប្រភេទ (ពន្ធលើចំណូលរូបវន្តបុគ្គល, ពន្ធលើប្រាក់ចំណូលសាជីវកម្ម, ពន្ធលើប្រាក់ចំណូលប្រេង, អាករលើតម្លៃបន្ថែម, ពន្ធអាជីវកម្មជាក់លាក់ និងពន្ធតែមប្រ៍) ស្ថិតនៅក្រោមចំណូល និងការអនុវត្តចំណូលប្រេង។

**គ. នាយកដ្ឋានគយថៃ** គឺជាអង្គភាពទទួលខុសត្រូវសម្រាប់ការប្រមូលពន្ធគយលើមុខទំនិញ ១៤ប្រភេទ និងសេវាកម្មចំនួន ០៤។ ទាក់ទងនឹងអត្រាពន្ធ នាយកដ្ឋានគយថៃប្រើប្រាស់អត្រាពន្ធជាច្រើនដូចជាពន្ធជាក់លាក់ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងប្រព័ន្ធចម្រុះ។ ការដាក់តែងពន្ធអាករពិសេស ត្រូវឈរលើមូលដ្ឋានចំនួន ០៣ គឺ÷ ផលប៉ះពាល់សុខភាព, ការប្រើប្រាស់ផលិតផលទំនើប, និងការប្រើប្រាស់

ទំនិញដែលប៉ះពាល់បរិស្ថាន។ នាយកដ្ឋានគយថៃប្រើប្រាស់រចនាសម្ព័ន្ធពន្ធលើស្រាដែលមានសមាសភាគពន្ធ ០៣ គឺផ្សព្វផ្សាយពាណិជ្ជកម្ម valorem + ជាក់លាក់ + លើសកម្រិតជាក់លាក់នៃស្រា, ខណៈពេលដែលមានសមាសភាគ ២ នៅលើអត្រាពន្ធលើថ្នាំជក់ - ផ្សព្វផ្សាយពាណិជ្ជកម្ម valorem + ជាក់លាក់។

## ប្រសិទ្ធភាពចំណូល-ចំណាយ និងនីតិវិធីអនុវត្ត សម្រាប់ហិរញ្ញវត្ថុសាធារណៈ

### ក. ការិយាល័យគោលនយោបាយធ្វើការប្រមូលចំណូលភ្ជាប់នឹងសមិទ្ធកម្មសេដ្ឋកិច្ច÷

ការចំណាយ ០៤ នៃការចំណាយរបស់រដ្ឋាភិបាលត្រូវបានផ្អែកលើគោលការណ៍គន្លឹះរចនាសម្ព័ន្ធថវិកា ដូចខាងក្រោម÷

- រចនាសម្ព័ន្ធ÷ស្ថានភាពសារពើពន្ធ និងសេដ្ឋកិច្ចបច្ចុប្បន្ន ឆ្លើយតបនឹងគោលនយោបាយរដ្ឋាភិបាល
- ការចំណាយបច្ចុប្បន្ន÷ប្រសិទ្ធភាព និងគ្រប់គ្រាន់;
- គោលការណ៍ការទូទាត់សង÷វិន័យ និងការគ្រប់គ្រងសារពើពន្ធឱ្យមានប្រសិទ្ធភាព;
- ការចំណាយមូលធន÷ ផ្តល់អាទិភាពដល់ការចំណាយមូលធនដោយពិចារណាពីយុទ្ធសាស្ត្ររបស់ប្រទេស និងការត្រៀមខ្លួនរួចរាល់របស់ទីភ្នាក់ងារអនុវត្ត។

ដើម្បីវាយតម្លៃពីថវិការបស់រដ្ឋាភិបាលថៃ ក្រសួងហិរញ្ញវត្ថុ ប្រើប្រាស់វិធីសាស្ត្រវិភាគដូចតទៅ ÷ ទិដ្ឋភាពម៉ាក្រូពីថវិកាដែលស្ថិតក្រោមការព្រួយបារម្ភរបស់ហិរញ្ញប្បទានថវិកាបិទ, កម្ចីនិងហិរញ្ញប្បទានខាងក្រៅ, ស្របជាមួយផែនការ និងយុទ្ធសាស្ត្រថ្នាក់ជាតិ, ការចែកចាយស្មើភាពគ្នា, ចៀសវាងការថតចម្លងប្រតិបត្តិការ, តម្លៃសម្រាប់ប្រាក់ និងតម្លៃសេដ្ឋកិច្ច, សមត្ថភាពស្របយក និងនីតិវិធីនឹងបន្តគម្រោងជាដើម។

> ប្រព័ន្ធនេះអាចចាត់ថ្នាក់អ្នកជាប់ពន្ធដោយផ្អែកលើជួរនៃប្រាក់ចំណូល និងប្រតិបត្តិការចុះឈ្មោះអ្នកជាប់ពន្ធនេះ ជាធម្មតាត្រូវបានធ្វើនៅលើបណ្តាញអនឡាញ។

**ខ. នាយកដ្ឋានចំណូល ÷** ដំណើរការនៃការបង្កើតគោលនយោបាយពន្ធនៅក្នុងប្រទេសថៃរួមមាន ÷

- ដាក់សំណើ និងវិក្កយបត្រទៅរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុសម្រាប់ការអនុម័ត
- រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនឹងបង្ហាញជូននូវសំណើ និងសេចក្តីព្រាងច្បាប់ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត
- សេចក្តីព្រាងច្បាប់នេះនឹងត្រូវបានពិនិត្យដោយក្រុមប្រឹក្សារដ្ឋមុនពេលត្រូវបានដាក់ជូនទៅព្រះមហាក្សត្រ



ចុះហត្ថលេខា។ នាយកដ្ឋានចំណូល នឹងបង្កើតច្បាប់ និងបទប្បញ្ញត្តិថ្មី ពាក់ព័ន្ធការអនុវត្តច្បាប់នេះ។

ជាឧទាហរណ៍ ការិយាល័យចំណូលតំបន់ទី ៤ ទីក្រុងបាងកក (Baro 4)÷ ការិយាល័យនេះត្រូវបានគ្រប់គ្រងពន្ធលើប្រាក់ចំណូលសាជីវកម្ម (៣១.៨៥%), ពន្ធប្រាក់ចំណូលផ្ទាល់(៦៧.៧៣%) និងអ្នកជាប់ពន្ធដែលមានទំហំធំ(០.៤២%)។ ជាទូទៅ ប្រព័ន្ធចងក្រងការបង់ពន្ធគឺជាមូលដ្ឋានកុំព្យូទ័រ និងអ្នកជាប់ពន្ធទទួលខុសត្រូវសម្រាប់ការចុះបញ្ជី, ការដាក់ស្នើកក់(វិក្កយបត្រ និងឯកសារអាករលើតម្លៃបន្ថែមជាដើម) ខណៈពេលដែលការិយាល័យទី៤ បង្ហាញការត្រួតពិនិត្យប្រព័ន្ធ និងពីរបៀបត្រួតពិនិត្យប្រព័ន្ធនេះ បានដកស្រង់ទិន្នន័យ និងផ្ទៀងផ្ទាត់ទិន្នន័យ។ ប្រព័ន្ធនេះអាចចាត់ថ្នាក់អ្នកជាប់ពន្ធដោយផ្អែកលើជួរនៃប្រាក់ចំណូល និងប្រតិបត្តិការចុះឈ្មោះអ្នកជាប់ពន្ធនេះ ជាធម្មតា ត្រូវបានធ្វើនៅលើបណ្តាញអនឡាញ។

**ឥ. នាយកដ្ឋានគយ និងរដ្ឋាករ÷** ការតាក់តែងពន្ធអាករពិសេស ត្រូវឈរលើមូលដ្ឋានចំនួន ០៣ គឺ ÷ ផលប៉ះពាល់សុខភាព, ការប្រើប្រាស់ផលិតផលទំនើប, និងការប្រើប្រាស់ទំនិញដែលប៉ះពាល់ដល់បរិស្ថាន។ នៅឆ្នាំសារពើពន្ធឆ្នាំ២០១៥ ការប្រមូលប្រាក់ចំណូលរបស់នាយកដ្ឋានគយថៃ ១៧% គឺប្រហែល ១២.៥៥ ប៊ីលានដុល្លារអាមេរិកនៃប្រាក់ចំណូលសរុប ដែលផលិតផលប្រេងបានឈរលំដាប់ដំបូងដែលមានចំនួន ២៩% ឬស្មើនឹង ៣.៦ប៊ីលានដុល្លារអាមេរិកនៅរង្វង់ភាគរយដូចតទៅ÷ រថយន្ត ១៩%, ស្រាបៀរ ១៨%, ស្រា១៤%, ផលិតផលថ្នាំជក់ចំនួន ១៤%, ភេសជ្ជៈដែលមិនមានជាតិអាល់កុល ៤%និងផ្សេងទៀត ២%។ នៅ ឆ្នាំ២០១៦ គ្រាន់តែបានផ្លាស់ប្តូររចនាសម្ព័ន្ធពន្ធថ្មីរបស់នាយកដ្ឋានគយថៃ នឹងមានប្រសិទ្ធភាពលើ រថយន្តដោយជំនួសមូលដ្ឋានពន្ធលើទំហំម៉ាស៊ីនទៅមូលដ្ឋានបំភាយឧស្ម័ន $CO_2$ ពន្ធលើរថយន្ត គឺជាការលើកទឹកចិត្តមួយដើម្បីកាត់បន្ថយបន្ទុកផ្នែកបរិស្ថាន និងការអភិរក្សបរិស្ថាន, ការគាំទ្រផលិតផលក្នុងស្រុក និងការសន្សំថាមពលជាដើម។

## ឧត្តមានុវត្តន៍សម្រាប់ពិចារណា ឬការសម្រេចចិត្តរបស់នាយកដ្ឋានគយ÷

- អត្រាពន្ធគួរត្រូវកំណត់សមហេតុសមផល,តុល្យភាពរវាងគោលនយោបាយពន្ធ និងរដ្ឋបាលសារពើពន្ធ និងអ្នកបង្កើតគោលនយោបាយគួរយល់ពីតម្រូ, ការបត់បែននៃតម្រូវការ និងវប្បធម៌ ដូចជាបទពិសោធសម្រាប់នាយកដ្ឋានគយថៃ, អត្រាពន្ធខ្ពស់, ការកើតឡើងការរត់ពន្ធជាច្រើនទៀតនិងប្រាក់ចំណូលនឹងកាត់បន្ថយ ខណៈពេលដែលការប្រើប្រាស់នៅតែមានដូចគ្នា
- ការងារកែទម្រង់គយគួរតែត្រូវបានអនុវត្តជាក់ស្តែងដែលមានន័យថារបៀបដែលវាប៉ះពាល់ដល់ការប្រើប្រាស់,ការវិនិយោគ និងការជំនួសក្នុងការទទួលបានប្រសិទ្ធភាពជាអតិបរមា
- ការផ្តល់រចនាសម្ព័ន្ធពន្ធ និងការលើកទឹកចិត្ត, ការលើកកម្ពស់ការប្រកួតប្រជែងពន្ធក្នុងស្រុក។ ឧទាហរណ៍ ការលើកទឹកចិត្តពន្ធលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការដកពន្ធ ជាដើម
- កម្ពុជាគួរគិតគូរអំពីការប្រើប្រាស់គយក្នុងកិច្ចការជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក និងលើកស្ទួយសហគ្រាសក្នុងស្រុក។ ក្បិត គ្រប់ភាពជោគជ័យសម្រាប់សេដ្ឋកិច្ចមួយប្រកបដោយភាពរឹងមាំ គឺផលិតផលក្នុងស្រុក ប៉ុន្តែត្រូវមានសមភាពរវាងទំនិញនាំចូលផងដែរ
- ការកំណត់ពន្ធគយឱ្យកាន់តែលម្អិតមានន័យថាការប្រើប្រាស់គោលនយោបាយកាន់តែមានប្រសិទ្ធភាព និងចំគោលដៅ។ ជាឧទាហរណ៍ អាករពិសេសលើផលិតផលស្រា និងស្រាបៀរ មានទាំងពន្ធអាករ និងមិនមែនពន្ធអាករទាប ជំរុញឱ្យការគេចវេសពន្ធនាំចូលផលិតផលត្រូវបានកាត់បន្ថយផងដែរ
- រដ្ឋចង់បង្កើនប្រាក់ចំណូល ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច ក៏ដូចជាសុខុមាលភាពហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ក្នុងន័យនេះ *តើយើងគួរបង្កើនអត្រាពន្ធ ឬយ៉ាងណា?* ពីព្រោះថាពេលខ្លះការបង្កើនអត្រាពន្ធអាករពិសេស ប្រហែលជាយើងប្រមូលចំណូលមិនបានអ្វីសោះ ឬតិចជាងអ្វីដែលយើងរំពឹងទុក
- ការប្រមូលបានទិន្នន័យត្រឹមត្រូវ និងប្រកបដោយគុណភាព ជាអ្វីដែលមិនអាចខ្វះបានសម្រាប់កិច្ចការរៀបចំគោលនយោបាយសារពើពន្ធរយៈពេលវែង
- ម្យ៉ាងវិញទៀតនៅប្រទេសថៃ មិនមានការយកពន្ធលើវត្ថុធាតុដើមដូចប្រទេសកម្ពុជាឡើយ។

## មេរៀនទទួលបានពីការងារកែទម្រង់ប្រព័ន្ធគោលនយោបាយ និងរដ្ឋបាលពន្ធថៃធៀបនឹងបរិបទប្រទេសកម្ពុជា

ខណៈពេលដែលប្រទេសកម្ពុជា ស្ថិតនៅទីតាំងនៃការពង្រឹងរដ្ឋបាលសារពើពន្ធ ការងារកែទម្រង់ដូចជាការស្វែងយល់ពីលទ្ធភាពការងារកែទម្រង់នយោបាយពន្ធធំ

ជាពិសេសពន្ធលើប្រាក់ចំណូល និងគយ និងបទពិសោធន៍ក្នុងការងារកែទម្រង់រដ្ឋបាលសារពើពន្ធថៃបានផ្តល់ជាមេរៀនល្អសម្រាប់ប្រទេសកម្ពុជា ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនទាំងការត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលសារពើពន្ធ។ ពិតណាស់បទពិសោធន៍ការងារកែទម្រង់នៅក្នុងប្រទេសថៃ បានបង្ហាញភ័ស្តុតាងរឹងមាំអំពីការលំបាក, ភាពធន់ទ្រាំ (resistance) និងជម្រើសដើម្បីដោះស្រាយទាំងនោះ។

ជាលទ្ធផល ការគូសបង្ហាញពីផលប៉ះពាល់មួយចំនួនសម្រាប់ប្រទេសកម្ពុជា ÷

- ការចែករំលែកទិន្នន័យគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន និងជាគន្លឹះជំរុញឱ្យគោលនយោបាយត្រឹមត្រូវក្នុងការរកឃើញគំរូនៃការប្រើប្រាស់ និងផលប៉ះពាល់ការវិនិយោគដែលពន្ធដារមិនទាន់បានចែករំលែក
- តម្លៃខ្ពស់នៃប្រេងសាំងនឹងលើកទឹកចិត្តប្រជាជនឱ្យប្រើប្រាស់ច្រើនលើមធ្យោបាយដឹកជញ្ជូនសាធារណៈត្បិតប្រទេសកម្ពុជាមានមធ្យោបាយដឹកជញ្ជូនសាធារណៈស្ថិតនៅកម្រិតមួយតិចតួច
- នាយកដ្ឋានចំណូលនេះ នឹងមានតួនាទីយ៉ាងសំខាន់នៅក្នុងការរចនា និងការអនុវត្តកំណែទម្រង់គោលនយោបាយពន្ធ។ បញ្ហាប្រឈមនៃការបង្កើតមូលដ្ឋានពន្ធដែលត្រូវបានគូសបង្ហាញដោយធនាគារពិភពលោក ក្នុងនោះពន្ធលើប្រាក់ចំណូលត្រូវកាត់បន្ថយពី ២៥% មក ១៧%វិញ (ការកាត់បន្ថយផ្នែកឯកជន ចំនួន ៤% និងផ្នែកគោលនយោបាយចំនួន ៤%។ ជាពិសេស គោលនយោបាយប្រទេសថៃអាចធ្វើការកែសម្រួលជារៀងរាល់ឆ្នាំ ត្បិតគោលនយោបាយដែលដាក់ចេញពិតជាមានវេទយិតភាពខ្លាំង
- ការកសាងសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) ដើម្បីកែលម្អឱ្យមានប្រសិទ្ធភាព និងគុណភាពការងារនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសការយកពន្ធលើចំណូលរូបវន្តបុគ្គល ប្រទេសថៃ ១.៥% (VAT ចំនួន៧% របស់ប្រទេសថៃស្ថិតក្នុងចំណាក់ថ្នាក់ទី៣ របស់ពិភពលោក) ដូច្នេះ ពន្ធលើចំណូលរូបវន្តបុគ្គលត្រូវផ្តោតជាសារវន្តលើ E-Payment ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ។ ការចំណាយនៃការប្រមូលប្រាក់ដុល្លារជាសូចនាករសមិទ្ធកម្មគន្លឹះនៅក្នុងនាយកដ្ឋានចំណូល ត្បិតការចំណាយទាបមានន័យថាមានប្រសិទ្ធភាពកាន់តែប្រសើរ( ០.៦% ថៃ)។ ចំណូលប្រមូលបានក្នុងឆ្នាំ ២០១៦ មានកំណើន ៤.៩% ខ្ពស់ជាងគោលដៅ និង ១១.១% ខ្ពស់ជាងឆ្នាំ២០១៥។

តារាងទី១: រចនាសម្ព័ន្ធថវិការបស់ប្រទេសថៃ

| រចនាសម្ព័ន្ធថវិកា | 2013FY | 2014 FY | 2015FY | 2016FY | 2017P |
|---|---|---|---|---|---|
| ចំណូលធៀបនឹង ផ.ស.ស | 17.5% | 16.6% | 17.2% | 14.5% | |
| ១. ចំណាយ | 2,400,000 | 2,525,000 | 2,575,000 | 2,776,000 | 2,733,000 |
| (ជាភាគរយ ផ.ស.ស) | 20.2% | 20.8% | 20.4% | 19.8% | 18.4% |
| ១.១ ចំណាយចរន្ត | 1,900,477 | 2,017,626 | 2,027,859 | 2,127,779 | 2,103,422 |
| (ជាភាគរយ ផ.ស.ស) | 16.0% | 16.6% | 16.1% | 15.2% | 77.0% |
| (ជាភាគរយនៃថវិកាសរុប) | 79.2% | 79.9% | 78.7% | 76.7% | 77.2% |
| ២. សក្ខីបត្រ | 2,100,000 | 2,275,000 | 2,325,000 | 2,776,000 | 2,733,000 |
| (ជាភាគរយ ផ.ស.ស) | 17.1% | 19.0% | 18.0% | 19.8% | 18.4% |
| ៣. កម្ចីក្នុងស្រុក | 300,000 | 250,000 | 250,000 | 390,000 | 390,000 |
| (ជាភាគរយ ផ.ស.ស) | 2.4% | 2.0% | 2.0% | 2.9% | 2.9% |
| ៤. ផ.ស.ស | 12,295,000 | 12,424,000 | 12,627,000 | 14,034,300 | 13,359,400 |

ចំណែកឯសូចនាករសមិទ្ធកម្មគន្លឹះប្រទេសកម្ពុជា ការយកពន្ធលើចំណូលរូបវន្តបុគ្គលចំនួន ០.២% ហាក់ពុំទាន់ទទួលបានទំនើបកម្មនៃការយកពន្ធនៅឡើយ ព្រោះថាប្រព័ន្ធបច្ចេកវិទ្យាហាក់នៅមានកម្រិត។ ត្បិតការយកពន្ធប្រាក់ចំណូលសាជីវកម្មរបស់ប្រទេសថៃ និងកម្ពុជា ចំនួន ២០% ដូចគ្នាក្នុងតំបន់អាស៊ាន និងស្ថិតក្នុងចំណាត់ថ្នាក់ទី៣។ ករណីកម្ពុជាក្នុងឆ្នាំ២០១៤, ២០១៥, ២០១៦ ការប្រមូលចំណូលពន្ធគឺ១.២៧%,១.១៦%, ១.២៧% ដោយយកចំណាយសរុបរដ្ឋបាលសារពើពន្ធធៀបនឹងចំណូលរកបានដោយរដ្ឋបាលគយ និងពន្ធដារ។ ត្បិតប្រទេសកម្ពុជាចំណូលប្រមូលបាន ក្នុងឆ្នាំ២០១៦ មានកំណើន ៣.៣% ខ្ពស់ជាងគោលដៅ និង ១៨.៨% ខ្ពស់ជាងឆ្នាំ ២០១៥។

តារាងទី២: ចំណូល និងចំណាយគិតជាឯកតា ផ.ស.ស របស់ប្រទេសកម្ពុជា

| | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017P |
|---|---|---|---|---|---|---|---|
| ចំណូលក្នុងស្រុក | 12.9 | 15.2 | 15.2 | 17.0 | 18.0 | 17.9 | 18.2 |
| ១.ចំណូលចរន្តសរុប | 13.0 | 14.7 | 15.1 | 16.8 | 17.8 | 17.7 | 18.2 |
| ១.១.ចំណូលពន្ធគយ | 6.0 | 6.5 | 6.4 | 8.0 | 8.3 | 8.3 | 18.1 |
| ១.២.ចំណូលពន្ធដារ | 4.5 | 5.3 | 5.9 | 6.3 | 7.1 | 7.1 | 8.3 |
| ១.៣.ផ្សេងៗ | 2.5 | 3.0 | 2.7 | 2.5 | 2.4 | 2.4 | 7.7 |
| ២.ចំណាយសរុប | 21.0 | 21.9 | 22.0 | 21.6 | 20.9 | 22.8 | 2.2 |
| ២.១.ចំណាយចរន្ត | 11.4 | 12.1 | 12.3 | 12.7 | 13.0 | 14.7 | 14.8 |
| ២.២.ចំណាយមូលធន | 9.6 | 9.8 | 9.7 | 8.8 | 7.8 | 8.0 | 8.4 |




ការបង្កើតគោលយោបាយសារពើពន្ធ, ការប្រមូលចំណូលពន្ធ, និងការប្រមូលចំណូលពន្ធគយរបស់ព្រះរាជាណាចក្រថៃកំពុងដំណើរការយ៉ាងរលូន។ ម្យ៉ាងវិញទៀត គុណភាពទិន្នន័យគ្រប់ជ្រុងជ្រោយពិតជាមានសារៈសំខាន់មិនអាចខ្វះបានក្នុងការរៀបចំគោលនយោបាយជាក់ស្តែង ប្រទេសថៃបានធ្វើទំនើបកម្មលើការកត់ត្រាទិន្នន័យ និងការចុះពិធីសារផ្លាស់ប្តូរទិន្នន័យរវាងស្ថាប័នពាក់ព័ន្ធ។ ■

# តើមានអ្វីប្លែក ក្នុងក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ឆ្នាំ២០១៦?

ការវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានឧបករណ៍ជាច្រើន ហើយឧបករណ៍នីមួយៗ មានមុខងារខុសប្លែកគ្នា។ ជាក់ស្តែង ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA) ត្រូវបានបង្កើតឡើង ក្នុងគោលបំណង ធ្វើការវាយតម្លៃ និងរៀបចំជារបាយការណ៍នូវភាពខ្លាំង និងភាពខ្សោយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់សូចនាករបែបបរិមាណធ្វើការវាយតម្លៃ។

ការវាយតម្លៃនេះ គឺជាធាតុចូលសម្រាប់កែលម្អប្រព័ន្ធរបស់ប្រទេសមួយ ដោយប្រៀបធៀបនឹងស្តង់ដារអន្តរជាតិ ក្នុងគោលដៅធានាបាននូវវិន័យថវិកា, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។

ក្របខ័ណ្ឌ PEFA ត្រូវបានរៀបចំឡើង តាំងពីឆ្នាំ២០០៥ និងត្រូវបានកែសម្រួលចំនួន ២ លើករួចមកហើយ ដែលលើកទី១ នៅឆ្នាំ២០១១ និងលើកទី២ នៅឆ្នាំ២០១៦ ដើម្បីឱ្យស្របតាមបរិបទនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនាពេលបច្ចុប្បន្ន។ ក្របខ័ណ្ឌ PEFA ២០១៦ ត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៦។ តាំងពីប្រកាសដាក់ឱ្យអនុវត្តនៅឆ្នាំ២០០៥ ក្របខ័ណ្ឌ PEFA ត្រូវបានយកទៅប្រើប្រាស់សម្រាប់ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈច្រើនជាង ៥០០ លើក ក្នុងប្រទេសចំនួន ១៥០។

ការប្រើប្រាស់ក្របខ័ណ្ឌ PEFA ២០១៦ បង្ហាញនូវចំណុចសំខាន់ថ្មីចំនួន ១០ ដូចខាងក្រោម÷

- គាំទ្រសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- ពង្រឹងការវិភាគនៃការវាយតម្លៃការ



គ្រប់គ្រងចំណូលរបស់រដ្ឋាភិបាល

- បន្ថែមសសរស្តម្ភទី៧ លើការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល
- បន្ថែមសូចនាករដែលផ្តោតលើទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បញ្ចូលសូចនាករ D1, D2 និង D3 ដែលពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ ក្នុងសូចនាករវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុក្នុងប្រទេស
- បង្កើនការផ្តោតលើការរៀបចំផែនការ និងថវិការយៈពេលមធ្យម
- ពង្រឹងតម្លាភាពថវិកា
- បង្កើនសង្គតិភាពវិធីសាស្ត្រវាយតម្លៃ និងពាក្យបច្ចេកទេស
- អនុវត្តប្រព័ន្ធដាក់ពិន្ទុកាន់តែច្បាស់ និងសាមញ្ញ
- បង្កើតរចនាសម្ព័ន្ធរបាយការណ៍កាន់តែសាមញ្ញ និងងាយស្រួល។

ក្របខ័ណ្ឌ PEFA ឆ្នាំ២០១៦មានសសរស្តម្ភចំនួន ០៧ និងបែងចែកចេញជា ៣១ សូចនាករ និង៩៤ សមាសធាតុ។ សសរស្តម្ភទាំង ០៧ រួមមាន÷

១. *ភាពជឿទុកចិត្តនៃថវិកា* មាន ០៣ សូចនាករ និង០៦ សមាសធាតុ

២. *តម្លាភាពថវិកា* មាន ០៥ សូចនាករ និង ១២ សមាសធាតុ

៣. *ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល* មាន ០៤ សូចនាករ និង ១៣ សមាសធាតុ

៤. *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* មាន០៥ សូចនាករ និង ១៧ សមាសធាតុ

៥. *ការប៉ាន់ប្រមាណ និងការអនុវត្តថវិកា* មាន០៨ សូចនាករ និង ២៨ សមាសធាតុ

៦. *គណនេយ្យ និងបំណុល* មាន ០៣ សូចនាករ និង ១០ សមាសធាតុ

ដ្យាក្រាម÷ ការផ្លាស់ប្តូរក្របខ័ណ្ឌវាយតម្លៃឆ្នាំ២០១១ និងឆ្នាំ២០១៦



៧. *ការត្រួតពិនិត្យខាងក្រៅ និងសវនកម្ម* មាន ០២ សូចនាករ និង ០៨ សមាសធាតុ។

> ក្របខ័ណ្ឌ PEFA ត្រូវបានយកទៅប្រើប្រាស់សម្រាប់ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈច្រើនជាង ៥០០ លើក ក្នុងប្រទេសចំនួន ១៥០។

ដ្យាក្រាមនេះ បង្ហាញស្ទើរតែគ្រប់សូចនាករក្នុង PEFA ២០១១ គឺត្រូវបានដាក់បញ្ចូលក្នុងក្របខណ្ឌ PEFA ២០១៦ ប៉ុន្តែចំនួនសមាសធាតុ និងវិធីសាស្ត្រវាយតម្លៃ មានការប្រែប្រួល។ ទន្ទឹមនឹងនេះ ប្រហែល ៤០% នៃសមាសធាតុក្របខ័ណ្ឌ PEFA ២០១៦ គឺអាចប្រៀបធៀបដោយត្រង់ ឬដោយប្រយោលជាមួយសមាសធាតុក្របខ័ណ្ឌPEFA ២០១១, ១/៣ នៃសមាសធាតុខុសប្លែកពីក្របខណ្ឌ PEFA ២០១១ និង ១/៤ មានកម្មវត្ថុដូចគ្នា ប៉ុន្តែវិធីសាស្ត្រវាយតម្លៃ គឺខុសគ្នា។

ជារួម ក្របខ័ណ្ឌPEFA ថ្មីនេះ គឺមានគ្រប់ជ្រុងជ្រោយនៃទិដ្ឋភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឆ្លុះបញ្ចាំងនូវសុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាក់ស្តែង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) នឹងប្រើប្រាស់ក្របខ័ណ្ឌ PEFA ២០១៦ សម្រាប់ការវាយតម្លៃក្នុងឆ្នាំ២០២០ ដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកែលម្អក្របខ័ណ្ឌផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមស្តង់ដារអន្តរជាតិ។ ជាទិសទៅសម្រាប់ការវាយតម្លៃក្នុងឆ្នាំ ២០២០ ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់, អ.គ.ហ. នឹងពង្រឹងសមត្ថភាពមន្ត្រីជំនាញបន្ថែម ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីក្របខ័ណ្ឌវាយតម្លៃនេះដល់អង្គភាពពាក់ព័ន្ធ ដើម្បីងាយស្រួលក្នុងការសម្របសម្រួល និងកិច្ចសហការ។ ■

តារាង÷ ការប្រៀបធៀបសមាសធាតុរវាងក្របខ័ណ្ឌ PEFA ២០១៦ និង២០១១

| សូចនាករ PEFA ២០១៦ | ប្រៀបធៀប | សូចនាករ PEFA ២០១១ |
|---|---|---|
| ១៤ សមាសធាតុ | ការដាក់ពិន្ទុអាចប្រៀបធៀបគ្នា (កម្មវត្ថុ, តម្រូវការទិន្នន័យ និងវិធីសាស្ត្រវាយតម្លៃ) | ១៤ សមាសធាតុ |
| ២៤ សមាសធាតុ | ការដាក់ពិន្ទុអាចប្រៀបធៀបមិនចំពោះ (កម្មវត្ថុ និងទិន្នន័យ ដូចគ្នា) | ២៤ សមាសធាតុ |
| ២៥ សមាសធាតុ | ឈ្មោះ គឺអាចប្រៀបធៀបតែប៉ុណ្ណោះ (សូចនាករត្រូវបានរក្សាដដែល ប៉ុន្តែ វិសាលភាព, តម្រូវការ ឬវិធីសាស្ត្រវាយតម្លៃត្រូវបានផ្លាស់ប្តូរ) | ២៨ សមាសធាតុ |
| - | មិនអាចប្រៀបធៀប ដោយសារសមាសធាតុនេះ មិនត្រូវដាក់បញ្ចូលក្នុងក្របខណ្ឌថ្មី | ១០ សមាសធាតុ |
| ៣១ សមាសធាតុ | មិនអាចប្រៀបធៀបដោយជាសមាសធាតុថ្មីដែលមិនមានក្នុងក្របខ័ណ្ឌចាស់ | - |
| **សរុប ៩៤ សមាសធាតុ** | | **សរុប ៧៦ សមាសធាតុ** |

# រដ្ឋបាលថ្នាក់ក្រោមជាតិ នៅប្រទេសកម្ពុជា

វិមជ្ឈការបានផ្តល់ជូនអាជ្ញាធរមូលដ្ឋាន នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីមួយៗ នូវលក្ខន្តិកៈគតិយុត្ត ជានីតិបុគ្គលនៃនីតិសាធារណៈ នៅថ្នាក់ក្រោមជាតិ ដែលមានស្វ័យភាពគតិយុត្ត ដាច់ចេញពីរដ្ឋ ហៅថា “**រដ្ឋបាលថ្នាក់ក្រោមជាតិ**”។

ថ្មីៗនេះ វិមជ្ឈការនៅប្រទេសកម្ពុជាមានសញ្ញាណប្រហាក់ប្រហែលនឹងឧត្តមានុវត្តន៍អន្តរជាតិក៏ពិតមែន ក៏ប៉ុន្តែការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅប្រទេសកម្ពុជា ក៏មានលក្ខណៈពិសេសដោយឡែកផងដែរ។ ដូចនេះ អ្វីទៅជារដ្ឋបាលថ្នាក់ក្រោមជាតិ តាមច្បាប់កម្ពុជា?

## ក. ឧត្តមានុវត្តន៍អន្តរជាតិ

តាមរយៈវិមជ្ឈការ រដ្ឋផ្ទេរប្រតិភូកម្មសិទ្ធិអំណាច និងសមត្ថកិច្ច***មួយចំនួន*** ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយ ដែលអាចជា រាជធានី/ខេត្ត, ឬ ក្រុង/ស្រុក/ខណ្ឌ ឬ ឃុំ/សង្កាត់ ដែលរដ្ឋយល់ថាការសម្រេច និងការអនុវត្តដោយផ្ទាល់ដោយអាជ្ញាធរមូលដ្ឋាន ***កម្រិតណាមួយនោះ*** នឹងមានប្រសិទ្ធភាពជាងការសម្រេចដោយរដ្ឋបាលកណ្តាល។

នៅតាមបណ្តាប្រទេសមួយចំនួន ដូចជានៅប្រទេសបារាំងជាដើម រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានហៅថា **Collectivités Territoriales** ដែលអាចបកប្រែជាភាសាខ្មែរបានថា “**សមូហភាពដែនដី**”។ ក្នុងច្បាប់បារាំង សមូហភាពដែនដី ត្រូវបានផ្តល់និយមន័យជា នីតិបុគ្គលនៃនីតិសាធារណៈ ដាច់ដោយឡែកពីរដ្ឋ។ សមូហភាពដែនដីទាំងនេះ មានស្វ័យភាពផ្នែករដ្ឋបាល



និងហិរញ្ញវត្ថុដូចរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា។ ចំពោះសមូហភាពដែនដី នៅប្រទេសបារាំង ប្រធានក្រុមប្រឹក្សាគឺជាប្រមុខអង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិនោះ ហើយទាំងក្រុមប្រឹក្សា និងអង្គប្រតិបត្តិ គឺជារចនាសម្ព័ន្ធស្ថាប័ននៃសមូហភាពដែនដីនោះតែម្តង។ រីឯគណៈអភិបាល ឬអភិបាល តំណាងឱ្យរដ្ឋ ដើម្បីធ្វើការត្រួតពិនិត្យលើនីត្យានុកូលភាពនៃការអនុវត្តសកម្មភាពរបស់សមូហភាពដែនដី ឬរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះទៅនឹងច្បាប់របស់រដ្ឋ។

ទោះមានសណ្ឋានផ្សេងៗ តាមរដ្ឋនីមួយៗក៏ដោយ ក៏ប៉ុន្តែ ជាទូទៅ មានលក្ខណ្ឌគ្រឹះចំនួន ៣ ដែលកំណត់លក្ខណៈសម្បត្តិអាជ្ញាធរមួយជារដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមាន ***បុគ្គលភាពគតិយុត្ត, អង្គភាពដែលកើតចេញពីការបោះឆ្នោត (ទោះផ្ទាល់ ឬមិនផ្ទាល់) និងការផ្ទេរសមត្ថកិច្ច***។




## ក.១. បុគ្គលភាពគតិយុត្ត

បុគ្គលភាពគតិយុត្ត ផ្តល់ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិនូវស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗក្នុងសមត្ថកិច្ចដែលច្បាប់បានផ្តល់អោយ។ ក្នុងន័យនេះ រដ្ឋត្រូវផ្តល់ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរនូវមធ្យោបាយទាំងឡាយដែលធានាដល់ការបំពេញសមត្ថកិច្ច និងតួនាទីប្រកបដោយជោគជ័យ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមាន បេតិកភណ្ឌផ្ទាល់ខ្លួន មានទ្រព្យសម្បត្តិ មានបុគ្គលិក មានស្វ័យភាពហិរញ្ញវត្ថុ ដោយមានថវិកាផ្ទាល់ខ្លួន មានសិទ្ធិ និងកាតព្វកិច្ច រួមទាំងសិទ្ធិក្នុងការប្តឹង និងការពារខ្លួននៅមុខតុលាការផងដែរ។ បុគ្គលភាពគតិយុត្ត ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នូវស្វ័យភាពក្នុងធ្វើសេចក្តីសម្រេចសម្រាប់បញ្ហាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន តែមិនមែនក្នុងនាមរដ្ឋ ឬរដ្ឋបាលកណ្តាលឡើយ។ ម្យ៉ាងទៀត នីតិបុគ្គលដែនដីទាំងនេះ ទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះទង្វើខុសច្បាប់ទាំងឡាយដែលត្រូវបានប្រព្រឹត្តក្នុងក្របខណ្ឌនៃដែនសមត្ថកិច្ចការងាររបស់ខ្លួន។

តាមរយៈវិមជ្ឈការ រដ្ឋផ្ទេរប្រតិភូកម្មសិទ្ធិអំណាច និងសមត្ថកិច្ច ***មួយចំនួន*** ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាមួយ ដែលអាចជារាជធានី/ខេត្ត, ឬ ក្រុង/ស្រុក/ខណ្ឌ ឬឃុំ/សង្កាត់




## ក.២. ការគ្រប់គ្រងដោយក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត

នៅក្នុងប្រព័ន្ធវិមជ្ឈការ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតំណាងដោយមនុស្សមួយក្រុមដែលរៀបចំក្រោមទម្រង់ជា "**ក្រុមប្រឹក្សា**"។ ក្រុមប្រឹក្សា មានសមាជិកដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ ឬ មិនផ្ទាល់។ ជាទូទៅ ក្រុមប្រឹក្សាមានប្រធាន ០១ រូប អមដោយអនុប្រធានមួយចំនួន និងសមាជិក ហើយក្រុមប្រឹក្សាជាអ្នកមានសិទ្ធិអំណាចក្នុងការចេញសេចក្ដីសម្រេចផ្សេងៗក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ដែលផ្តល់ដោយច្បាប់ ដើម្បីការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

## ក.៣. ការផ្ទេរមុខងារ ឬសមត្ថកិច្ច

វិមជ្ឈការ គឺជាការផ្ទេរមុខងារ ឬ សមត្ថកិច្ចពីរដ្ឋ (ក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃ និងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា។ ការផ្ទេរមុខងារ ឬសមត្ថកិច្ចនេះ អាចជា***ការប្រគល់ជូន*** (assignment of function) ឬ ***ការធ្វើប្រតិភូកម្ម***

(delegation of function)។ ***ការប្រគល់ជូនមុខងារ*** ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានន័ យថា រដ្ឋផ្ទេរនូវភាពជាម្ចាស់តែម្តងលើមុ ខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ។ ដោយឡែក ***ប្រតិភូកម្មមុខងារ*** គឺជាការផ្ទេរមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។

## ២. ករណីប្រទេសកម្ពុជា

### ២.១. រដ្ឋបាលឃុំ សង្កាត់

របបគតិយុត្តថ្មីនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ រីឯការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបើកផ្លូវដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។ ច្បាប់ទាំងពីរនេះត្រូវបានអនុម័ត និងប្រកាសអោយប្រើនៅក្នុងឆ្នាំ២០០១។




សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាពលរដ្ឋ។

ប្រធានក្រុមប្រឹក្សាគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ តើប្រធានក្រុមប្រឹក្សាឃុំ ជានរណា ហើយគាត់មានតួនាទីអ្វី?

មាត្រា២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា÷ *រដ្ឋបាលឃុំសង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់។* ***ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជា មេឃុំ ចៅសង្កាត់***។

នៅថ្នាក់ក្រោមជាតិ ក៏ដូចជានៅថ្នាក់ជាតិ សមត្ថកិច្ចនៃការគ្រប់គ្រងត្រូវបានបែងចែករវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ នៅថ្នាក់ក្រោមជាតិ អំណាចបញ្ញត្តិ បានន័យថា អំណាចចេញសេចក្តីសម្រេចជារបស់ក្រុមប្រឹក្សា រីឯអំណាចក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានផ្តល់ទៅឱ្យអង្គប្រតិបត្តិមួយរបស់ក្រុមប្រឹក្សា។ តើអ្នកណាជាអ្នកដឹកនាំអង្គប្រតិបត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់? មាត្រា២៥ ខាងលើបានបញ្ញត្តថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជា មេឃុំ

ចៅសង្កាត់។ ក្នុងនាមជាប្រមុខអង្គប្រតិបត្តិរបស់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជាអ្នកគ្រប់គ្រងកិច្ចការប្រចាំថ្ងៃរបស់ឃុំ និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្នុងឋានៈជាប្រធានក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ ដឹកនាំអង្គប្រជុំ សម្របសម្រួលការប្រជុំរបស់ក្រុមប្រឹក្សា។ សរុបមក មេឃុំ ចៅសង្កាត់ ជាប្រធានក្រុមប្រឹក្សាផង និងជាប្រមុខអង្គប្រតិបត្តិ របស់ឃុំ សង្កាត់ផង។

ការរៀបចំរចនាសម្ព័ន្ធបែងចែកការងារបែបនេះ ដូចគ្នានឹងវិមជ្ឈការនៅប្រទេសបារាំងដែរ ព្រោះនៅទីនោះ ប្រធានក្រុមប្រឹក្សា គឺសុទ្ធតែជាប្រមុខនៃអង្គប្រតិបត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ។ ប្រធាននោះដឹកនាំអង្គប្រជុំរបស់ក្រុមប្រឹក្សាផង និងជាអ្នកដឹកនាំការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាផង។ ប្រធានក្រុមប្រឹក្សាឃុំ ជាប្រមុខអង្គប្រតិបត្តិឃុំ។ ប្រធានក្រុមប្រឹក្សាស្រុក ជាប្រមុខអង្គប្រតិបត្តិស្រុក។ ប្រធានក្រុមប្រឹក្សាខេត្ត ជាប្រមុខអង្គប្រតិបត្តិខេត្ត។ ក្នុងប្រទេសខ្លះទៀតនៅអឺរ៉ុប ប្រធានក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ជាមនុស្សផ្សេងក្រៅពីប្រមុខអង្គប្រតិបត្តិនៃរដ្ឋបាលថ្នាក់ក្រោមជាតិនោះ ៖ ឧទាហរណ៍ នៅប្រទេសអេស្តូនី ប្រធានក្រុមប្រឹក្សាឃុំ ជាបុគ្គលផ្សេងពីមេឃុំដែលជាប្រធានអង្គប្រតិបត្តិរបស់ឃុំ។

ផ្ទុយទៅវិញប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមែនជាប្រមុខអង្គប្រតិបត្តិនោះឡើយ។

## ខ.២. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៖ ក្រុមប្រឹក្សា និងគណៈអភិបាល

ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ថារដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយ រដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងដោយក្រុមប្រឹក្សា។




តាមរយៈវិមជ្ឈការ រដ្ឋបង្កើតអោយមាននីតិបុគ្គលសាធារណៈ នៅថ្នាក់ក្រោមជាតិ។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ជានីតិបុគ្គលនៃនីតិសាធារណៈ។

ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានសិទ្ធិអំណាចក្នុងការសម្រេចលើការរៀបចំទទួលមុខងារ ភារកិច្ច និងធនធានថ្មី, សម្រេចលើកម្មវិធីវិនិយោគ, ផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ, គម្រោងថវិកាប្រចាំឆ្នាំ, ការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធាន រួមទាំង គណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា, ការគ្រប់គ្រងនិងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋជាដើម។

ដោយឡែក គណៈអភិបាល ជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ក៏ប៉ុន្តែអភិបាល និងអភិបាលរង មិនមែនជាសមាជិករបស់ក្រុមប្រឹក្សាឡើយ។ លើសពីនេះ មាត្រា១៥៣ នៃច្បាប់ខាងលើ បានកំណត់ថាអភិបាល តំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។ គណៈអភិបាលត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ គណៈអភិបាលត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តនូវកម្មវិធីវិនិយោគ៣ឆ្នាំ រំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នជារៀងរាល់ឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដែលត្រូវរាយការណ៍ជូនប្រជាពលរដ្ឋរបស់ខ្លួន។ ម៉្យាងទៀត ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលត្រូវចាត់វិធានការដើម្បីធានាអោយមន្ត្រី អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទីភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព។ គណៈអភិបាល មិនមែនជាស្ថាប័នដែលកើតចេញពីការបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅមូលដ្ឋានទេ ហើយក៏មិនមែនកើតចេញពីក្រុមប្រឹក្សាដែលបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនោះដែរ។ គណៈអភិបាលត្រូវតែងតាំងឡើងដោយរដ្ឋបាលកណ្តាល ដែលមានព្រះមហាក្សត្រ (ព្រះរាជក្រឹត្យ) នាយករដ្ឋមន្ត្រី (អនុក្រឹត្យ) និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ប្រកាស)។

ជាក់ស្តែង នៅក្នុងនីតិវិធីថវិកា គណៈអភិបាល ជាអ្នកទទួលបន្ទុករៀបចំ និងបូកសរុបនូវផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាទាំងនេះ ត្រូវពិភាក្សា និងអនុម័តដោយក្រុមប្រឹក្សា រីឯការអនុវត្តថវិកា គឺស្ថិតជាសមត្ថកិច្ចរបស់គណៈអភិបាល។

ជារួម គេអាចសន្និដ្ឋានបានថា រដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសកម្ពុជា គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលតំណាងដោយក្រុមប្រឹក្សា។ ក្រុមប្រឹក្សា គឺជាអង្គនីតិបញ្ញត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រីឯគណៈអភិបាលគឺជាអង្គនីតិប្រតិបត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទោះបីអភិបាល និងអភិបាលរងត្រូវបានតែងតាំងដោយអាជ្ញាធរថ្នាក់កណ្តាលក៏ដោយ។ ■

# វិធីសាស្ត្រដាក់ពិន្ទុសម្រាប់វាយតម្លៃផែនការសកម្មភាពដំណាក់កាលទី៣ (២០១៦)

## ផែនការសកម្មភាពរួមដំណាក់កាលទី៣ (២០១៦-២០១៨) ដែលគាំទ្រដោយផែនការសកម្មភាពលម្អិតរបស់ កសហវ (GDAP3), និងផែនការសកម្មភាពលម្អិតរបស់ក្រសួងស្ថាប័ន (MAP3) នឹងត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦។

ដើម្បីវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំវិធីសាស្ត្រដាក់ពិន្ទុបន្ថែមទៅលើយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលមានស្រាប់។ វិធីសាស្ត្រដាក់ពិន្ទុនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងច្បាស់លាស់ក្នុងការវាស់វែងលទ្ធផលនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣។ ដើម្បីឱ្យវិធីសាស្ត្រនេះអនុវត្តបានដោយ សុក្រឹតភាព និងប្រសិទ្ធភាព គឺតម្រូវឱ្យអគ្គនាយកដ្ឋានក្រោមឱវាទ កសហវ នឹងក្រសួង-ស្ថាប័ន ត្រូវរៀបចំផែនការសកម្មភាពលម្អិត ដោយកំណត់សូចនាករជាក់លាក់ (specific) អាចវាស់វែងបាន (measurable) អាចសម្រេចបាន (achievable) ត្រឹមត្រូវតាមមុខងារ (relevant) និងកំណត់ពេលវេលាជាក់លាក់ (time-bound) ច្បាស់លាស់។ លើសពីនេះទៅទៀត ផែនការសកម្មភាពលម្អិត ត្រូវមានសង្គតិភាពទាំងស្រុងទៅនឹងផែនការសកម្មភាពរួម ដំណាក់កាលទី៣។ ការដាក់ពិន្ទុការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ រួមមានការដាក់ពិន្ទុការអនុវត្តផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាននៃ កសហវ, ការដាក់ពិន្ទុផែនការសកម្មភាពរបស់ក្រសួងស្ថាប័ន និងការដាក់ពិន្ទុការអនុវត្តផែនការសកម្មភាពរួម កសហវ (Consolidated GDAP3)។ ការដាក់ពិន្ទុចែកចេញជាបួនកម្រិត គឺ កម្រិតចង្កោមសកម្មភាព, កម្រិតគោលបំណង, កម្រិតផ្នែក និងកម្រិតកម្មវិធី ដែលកម្រិតទាំងបួននេះត្រូវបានដាក់ចេញនៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣ និងត្រូវអនុវត្តនៅក្នុងផែនការសកម្មភាពលម្អិតដោយ កសហវ និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

**កម្រិតចង្កោមសកម្មភាព÷** ពិន្ទុសម្រាប់វាយតម្លៃចង្កោមសកម្មភាពបានមកពីពិន្ទុសរុបនៃសកម្មភាពលម្អិតដែលអនុវត្តដោយ កសហវ និងក្រសួង ស្ថាប័ន។ សកម្មភាពលម្អិតមានទម្ងន់ខុសៗគ្នាក្នុងការរួមចំណែកសម្រេចឱ្យបានសូចនាករគន្លឹះនៃចង្កោមសកម្មភាព។ ចំណែកឯទម្ងន់នៃសកម្មភាពលម្អិតនីមួយៗត្រូវកំណត់ទុកជាមុន និងត្រូវមានការយល់ព្រមគ្នារវាង អ.គ.ហ និងក្រសួង ស្ថាប័ន/អគ្គនាយកដ្ឋាន កសហវ។

**កម្រិតគោលបំណង÷** ពិន្ទុសម្រាប់វាយតម្លៃគោលបំណងបានមកពីពិន្ទុសរុបនៃចង្កោមសកម្មភាពទាំង៦៧ ដែលមានទម្ងន់ខុសៗគ្នាក្នុងការរួមចំណែកសម្រេចឱ្យបានសូចនាករគន្លឹះនៃគោលបំណង។ ចំណែកឯទម្ងន់ ត្រូវបានកំណត់ទុកជាមុន ។

**កម្រិតផ្នែក÷** ពិន្ទុសម្រាប់វាយតម្លៃផ្នែកបានមកពីពិន្ទុសរុបនៃគោលបំណងទាំង២១ ដែលមានទម្ងន់ខុសៗគ្នាក្នុងការរួមចំណែកសម្រេចឱ្យបានសូចនាករនៃផ្នែក។ ចំណែកឯទម្ងន់ត្រូវបានកំណត់ទុកជាមុន។

**កម្រិតកម្មវិធី÷** ពិន្ទុសម្រាប់វាយតម្លៃកម្មវិធីបានមកពីពិន្ទុសរុបទាំង៥ផ្នែក នៃផែនការសកម្មភាពរួមដំណាក់កាល ទី៣ ដែលមានទម្ងន់ខុសៗគ្នាក្នុងការរួមចំណែកសម្រេចឱ្យបានគោលបំណងនៃកម្មវិធី។ ចំណែកឯទម្ងន់ត្រូវបានកំណត់ទុកជាមុន។

វិធីសាស្ត្រដាក់ពិន្ទុសម្រាប់កម្រិតនីមួយៗ មានខ្លឹមសារ ទម្រង់ និងការអនុវត្តដូចគ្នាគ្រប់កម្រិតទាំងអស់ ដោយតារាងនីមួយៗ ចែកចេញជា ៥ កូឡោន និងមានអត្ថន័យដូចខាងក្រោមនេះ÷

**កូឡោនទី១÷** បង្ហាញពីលទ្ធផលចុងក្រោយ ដោយលទ្ធផលចុងក្រោយនីមួយៗសម្រេចបានមកពីការចូលរួមចំណែកពីលទ្ធផលក្នុងឆ្នាំ/ត្រីមាសនៃកូឡោនទី២។

**កូឡោនទី២÷** បង្ហាញពីលទ្ធផលក្នុងឆ្នាំឬត្រីមាស និងទម្ងន់របស់វា ដើម្បីចូលរួមចំណែកសម្រេចឱ្យបានលទ្ធផលចុងក្រោយ។ លទ្ធផលក្នុងឆ្នាំ/ត្រីមាសមានទម្ងន់ខុសៗគ្នា ហើយទម្ងន់សរុបនៃសកម្មភាពទាំងអស់គឺស្មើនឹង ១.០០ ដើម្បីសម្រេចបានលទ្ធផល

ចុងក្រោយ។

កូឡោនទី៣÷ បរិយាយពីសូចនាករគន្លឹះនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ/ត្រីមាសដែលមាននៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣ និងដែលបានកំណត់ឯកតា និងទម្ងន់ច្បាស់លាស់។ ការកំណត់ឯកតានៃសូចនាករគន្លឹះ អាចជាចំនួន ឬជាភាគរយតាមភាពសមស្របនៃការវាស់វែងបាននៃសូចនាករ នីមួយៗ។ លទ្ធផលក្នុងឆ្នាំ/ត្រីមាសអាចមានសូចនាករគន្លឹះចំនួនមួយ ឬច្រើនជាងមួយ។

កូឡោនទី៤÷ បង្ហាញពីការវាយតម្លៃលើគោលដៅនៃសូចនាករដែលសម្រេចបានដែលគោលដៅទាំងនោះត្រូវបានវាយតម្លៃជាភាគរយតាមកម្រិតនៃការសម្រេចបានដែលបានកំណត់ទុកជាមុន គឺ ចាប់ពី ៩១% ឡើងទៅ ស្មើល្អណាស់, ពី៨១% ដល់ ៩០% ស្មើល្អ, ពី៧១% ដល់ ៨០% ស្មើល្អបង្គួរ, ពី៦១% ដល់៧០% ស្មើមធ្យម និងទាបជាង ឬស្មើ៦០% ស្មើខ្សោយ។ជាទូទៅគោលដៅនៃសូចនាករដែលសម្រេចបានអាចជាភាគរយ, ជាចំនួនឬជាភាគរយនៃកំណើន ឬជាភាគរយ នៃការថយចុះ។

កូឡោនទី៥÷ បង្ហាញពីលទ្ធផលសរុបសម្រេចបានដែលក្នុងនោះមាន÷

លទ្ធផលសម្រេចបាន÷ អាចជាចំនួន ឬភាគរយនៃសូចនាករគន្លឹះដែលសម្រេចបានជាក់ស្តែង។

ពិន្ទុផ្ទាល់÷ ជាពិន្ទុផ្ទាល់ក្នុងឆ្នាំ/ត្រីមាសរបស់សូចនាករគន្លឹះនីមួយៗដែលសម្រេចបានដែលជាភាគរយតាមកម្រិតវាយតម្លៃទាំង៥។

ពិន្ទុសម្រួល÷ ជាពិន្ទុដែលត្រូវចូលរួមចំណែកដើម្បីសម្រេចឱ្យបានលទ្ធផលចុងក្រោយទៅតាមទម្ងន់ដែលបានកំណត់ទុកជាមុន។ ពិន្ទុសម្រួលគឺជាផលគុណនៃពិន្ទុផ្ទាល់នឹងភាគរយនៃទម្ងន់រួមចំណែក របស់សូចនាករនីមួយៗក្នុងកូឡោនទី៣។ ■

ឧទហរណ៍÷ គំរូតារាងដាក់ពិន្ទុសម្រាប់វាយតម្លៃ

| លទ្ធផលចុងក្រោយ (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់(២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន(៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ (%) | ពិន្ទុសម្រួល |
| | សកម្មភាពទី១ | 0.10 | | | | | | | | | | | |
| | សកម្មភាពទី២ | 0.20 | | | | | | | | | | | |
| | សកម្មភាពទី៣ | 0.40 | | | | | | | | | | | |
| | សកម្មភាពទី៤ | 0.10 | | | | | | | | | | | |
| | សកម្មភាពទ៥ | 0.20 | | | | | | | | | | | |
| លទ្ធផល | | 1.00 | | | | | | | | | | | |

# ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២ ក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះ បានឈានដល់ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា។



ឯកសារយុទ្ធសាស្ត្រខាងលើ បាន ប្រកាសអំពីបេសកកម្ម, ការប្តេជ្ញា, និងកិច្ចប្រឹងប្រែងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភារហូតមក ក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ដោយក្នុងនោះបានប្រកាន់ខ្ជាប់នូវការកំណត់យក÷ (១) ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាវិស័យអាទិភាព សម្រាប់ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច, ព្រមទាំងពង្រឹងភាពប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា និង (២) ការចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយទទួលស្គាល់ថាវិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គម និងការបញ្ចូលបច្ចេកវិទ្យាទំនើប និងនវានុវត្តភាព សំដៅបង្កើនប្រសិទ្ធភាពនិងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ។

ក្នុងគោលដៅនេះ ច្បាប់ស្តីពីសម្បទានត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០៧ ដែលមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្អែកឯកជន។ តែទោះជាយ៉ាងនេះក្តី ការរៀបចំ និងការគ្រប់គ្រងគម្រោងនៅមានភាពរប៉ាត់រប៉ាយ, ប្រើប្រាស់យន្តការចំពោះកិច្ច, និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលមិនអនុលោមតាមឧត្តមានុវត្តន៍ជាអន្តរជាតិ។

ក្នុងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ថ្មី ដែលកម្ពុជាទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាល បានពិនិត្យឃើញថា គោលនយោបាយនៃការជំរុញការវិនិយោគសាធារណៈ កំពុងស្ថិតក្នុងស្ថានភាពទ្វេទិស គឺមានទាំងបញ្ហាប្រឈម និងទាំងកាលានុវត្តភាព។

បញ្ហាប្រឈមធំៗដែលកម្ពុជាជួបប្រទះរួមមាន÷ (១) ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ និង (២) ការធ្លាក់ចុះ និងបាត់បង់នូវឥណទានសម្បទានកម្រិតខ្ពស់នាពេលខាងមុខ។

ស្របពេលជាមួយគ្នានេះ កាលានុវត្តភាពថ្មីៗរបស់កម្ពុជា រួមមាន÷ (១) ការងើបឡើងក្នុងសន្ទុះលឿនគួរឱ្យកត់សម្គាល់របស់វិស័យឯកជននៅកម្ពុជាជាងមួយទសវត្ស



ចុងក្រោយ និងការកើនឡើងនូវសំណើសុំវិនិយោគរបស់វិស័យឯកជន តាមទម្រង់ "សាងសង់-អាជីវកម្ម-ផ្ទេរ" ដែលជាទម្រង់មួយនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយផ្តោតជាពិសេស ក្នុងវិស័យផ្លូវថ្នល់, ស្ពាន និងថាមពល ជាដើម; និង (២) ការដាក់ចេញនូវយុទ្ធសាស្ត្រ ហិរញ្ញប្បទានថ្មីរបស់ដៃគូអភិវឌ្ឍន៍ធំៗក្នុងការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការរៀបចំយន្តការនេះ ទាំងក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ។

តាមរយៈនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ "គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០" ដែលត្រូវបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦។

ជាចក្ខុវិស័យ នៅមុនដំណាច់ឆ្នាំ២០២០ រាជរដ្ឋាភិបាលត្រូវបង្កើត និងអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។

គោលនយោបាយនេះ មានគោលបំណងជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័ន ហិរញ្ញវត្ថុក្នុងការចូលរួមស្តារ, កសាង, ប្រតិបត្តិការ, និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក។




គោលនយោបាយនេះ មានគោលដៅដាក់ចេញនូវយុទ្ធសាស្ត្រ, កំណត់យន្តការស្ថាប័ន, និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡាគ្នា ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យគោលបំណង និងគោលដៅខាងលើ គោល-

គោលនយោបាយនេះ មានគោលបំណងជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុក្នុងការចូលរួមស្ថាបនា, កសាង, ប្រតិបត្តិការ, និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត

នយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ដាក់ចេញនូវវិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ព្រមទាំងវិធានការគោលនយោបាយរយៈពេលមធ្យម និងវែង ចំនួន ០៤ ចំណុចធំៗ ដូចសង្ខេបក្នុងតារាងវិធានការគោលនយោបាយខាងក្រោម។

រាជរដ្ឋាភិបាល សង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ត “**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០**” ឱ្យបានជោគជ័យ សំដៅចូលរួមលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម លើដំណើរនៃមាតិរបស់កម្ពុជាឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព, និងភាពចុំថ្កើងរុងរឿង។ ■

## តារាងវិធានការគោលនយោបាយ

| វិធានការគោលនយោបាយ | សកម្មភាព | |
|---|---|---|
| | ឆ្នាំ២០១៦-២០១៨ | ឆ្នាំ២០១៩-២០២០ |
| ១. ការពិនិត្យនិងរៀបចំក្របខ័ណ្ឌគតិយុត្ត, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ | • ក្នុងដំណាក់កាលអន្តរកាល បង្កើតគណៈកម្មការអន្តរក្រសួង ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានភារកិច្ច÷ (១) ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងធ្វើវិសោធនកម្មតាមការចាំបាច់; (២) រៀបចំអនុក្រឹត្យ, ប្រកាស, លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមទាំងកិច្ចលទ្ធកម្មគម្រោង និង (៣) ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាសមិទ្ធលទ្ធភាពគម្រោងអាទិភាពទាំងនោះ (គណៈកម្មការអន្តរក្រសួង បណ្តោះអាសន្ន ត្រូវបានបង្កើតឡើងរួចហើយ តាមរយៈសេចក្តីសម្រេចលេខ ០៥០ សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦)។ ទន្ទឹមនេះ ជ្រើសរើសគម្រោងអាទិភាពចំនួន ២-៣ ដើម្បីដាក់ឱ្យអនុវត្តសាកល្បង។ | • ពិនិត្យ និងកែសម្រួលឡើងវិញតាមការចាំបាច់ ដើម្បីបង្កើតយន្តការស្ថាប័នអចិន្ត្រៃយ៍។<br>• ពិនិត្យ និងកែសម្រួលឡើងវិញតាមការចាំបាច់នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ, យន្តការស្ថាប័ន, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ។ |
| ២. ការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុ | • បង្កើត និងដាក់ឱ្យអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការសិក្សារៀបចំគម្រោង<br>• រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃមូលនិធិអភិវឌ្ឍន៍គម្រោង។ | • ពិនិត្យលទ្ធភាពលើការរៀបចំបង្កើតមូលនិធិបំពេញផលហិរញ្ញវត្ថុដែលមានគោលដៅផ្តល់ឧបត្ថម្ភធនដល់គម្រោងវិនិយោគសាធារណៈមួយចំនួនឱ្យមានភាពទាក់ទាញពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ។<br>• រៀបចំនីតិវិធីប្រតិបត្តិការនៃមូលនិធិបំពេញផលហិរញ្ញវត្ថុ។ |
| ៣. ការរៀបចំ និងកំណត់យន្តការស្ថាប័ន | • ធ្វើសមាហរណកម្មមុខងារនៃអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន និងអង្គភាពគ្រប់គ្រងហានិភ័យទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>• បង្កើត ឬធ្វើសមាហរណកម្មមុខងារនៃអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធ។ | • ពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងអង្គភាពគ្រប់គ្រងហានិភ័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>• ពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធ។ |
| ៤. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស | • រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ននិងធនធានមនុស្ស។ | • ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន និងធនធានមនុស្ស។ |

# បទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងមួយក្នុងចំណោមក្រសួងចំនួន ៧ ដែលបានដាក់ឱ្យអនុវត្តសាកល្បងដំបូងគេនូវថវិកាកម្មវិធីចាប់ពីឆ្នាំ២០០៧ ដោយដំណាក់កាលនោះថវិកាក្រសួងត្រូវបានបែងចែកជាពីរផ្នែកធំៗ គឺ ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី។

បន្ទាប់មក នៅឆ្នាំ២០១៥ ថវិកាកម្មវិធីត្រូវបានអនុវត្តពេញលេញ នៅក្រសួងអប់រំ យុវជន និងកីឡា មានន័យថាថវិកាមិនមែនកម្មវិធីត្រូវបញ្ចូលទៅក្នុងថវិកាកម្មវិធី ហើយថវិកាទាំងអស់ត្រូវតែគាំទ្រដល់គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពរបស់ក្រសួង។

ក្នុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា មានកម្មវិធីចំនួន ៥ និងអនុកម្មវិធីចំនួន ៣៩ ដែលត្រូវអនុវត្តដោយអង្គភាពថវិកាចំនួន ៦៤ ក្នុងនោះថ្នាក់រដ្ឋបាលកណ្ដាលមាន ៣៩ និងរាជធានីខេត្តចំនួន ២៥។ ចំនួនអង្គភាពថវិកា ត្រូវបានសម្រួលមកត្រឹមតែ ៦២ ក្នុងឆ្នាំ២០១៦ នេះ។

តាមវដ្តនៃការអនុវត្តថវិកាកម្មវិធី យោងតាមសារាចររបស់រាជរដ្ឋាភិបាល នៅកំឡុងខែមេសា និងឧសភា ក្រសួងចាំបាច់ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល (BSP) ដើម្បីគាំទ្រដល់គោលនយោបាយរបស់ខ្លួន។ ក្រោយមកក្នុងខែមិថុនា និងកក្កដា ក្រសួងត្រូវរៀបចំថវិកាប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រដែលមានស្រាប់ រួចហើយត្រូវត្រៀមខ្លួនការពារកញ្ចប់ថវិកានេះក្នុងខែសីហា និងកញ្ញា ទាំងក្នុងកម្រិតជំនាញ និងក្នុងកម្រិតថ្នាក់ដឹកនាំ។ ចុងក្រោយ ក្រសួងត្រូវរង់ចាំថវិកាអនុម័តពីរដ្ឋសភា ព្រឹទ្ធសភា និងចុះហត្ថលេខាដោយព្រះមហាក្សត្រ ទើបអាចអនុវត្តបន្តបាន។

ក្នុងការអនុវត្តថវិកាកម្មវិធី អង្គភាពថវិកាត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការគ្រប់គ្រង ការអនុវត្ត និងការទទួលខុសត្រូវទាំងឡាយ ជាពិសេសត្រូវទទួលរងសវនកម្មលើរបាយការណ៍ចំណាយរបស់ខ្លួន។ អង្គភាពថវិកានៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវស្វែងយល់ឱ្យបានច្បាស់នូវសកម្មភាព ចង្កោមសកម្មភាព អនុកម្មវិធី កម្មវិធី និងគោលនយោបាយរបស់អង្គភាពខ្លួន ហើយត្រូវធានាឱ្យបានថាការរៀបចំថវិកានឹងឆ្លើយតបនឹងសកម្មភាព និងចង្កោមសកម្មភាពទាំងនេះ។ នៅពេល



ចរចាថវិកា អង្គភាពថវិកានីមួយៗ ត្រូវតែបង្ហាញនូវហេតុផលច្បាស់លាស់ថាតើដើម្បីសម្រេចឱ្យបានសកម្មភាពមួយ អង្គភាពថវិកាត្រូវការចំនួនទឹកប្រាក់អនុវត្តប៉ុន្មាន។



ក្រោយពីថវិកាត្រូវបានអនុម័តពីរដ្ឋសភាហើយ ដើម្បីអនុវត្តថវិកាកម្មវិធីបាន អង្គភាពថវិកាទាំងអស់ត្រូវរៀបចំតែងតាំងរដ្ឋទេយ្យករ និងរដ្ឋទេយ្យកររងជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ។ រដ្ឋទេយ្យកររបស់អង្គភាពថវិកា ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានក្នុងទំហំទឹកប្រាក់មិនឱ្យលើសពី ៣០% នៃកញ្ចប់ថវិកាសរុបរបស់ខ្លួនឡើយ ដើម្បីអាចបើកប្រាក់រដ្ឋទេយ្យបុរេប្រទានពីរតនាគារជាតិសម្រាប់មួយជុំ ស្មើនឹងមួយភាគបួននៃឥណទានរដ្ឋទេយ្យបុរេប្រទានប្រចាំឆ្នាំ។ ក្នុងករណីដែលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានមិនអាចរៀបចំរួចរាល់ក្នុងខែមករាបាន នោះរតនាគារជាតិនឹង

ក្នុងការអនុវត្តថវិកាកម្មវិធី,
អង្គភាពថវិកាត្រូវបានផ្តល់សិទ្ធិ
អំណាចក្នុងការគ្រប់គ្រង ការ
អនុវត្ត និងការទទួលខុសត្រូវ
ទាំងឡាយ ជាពិសេសត្រូវទទួលរ
ងសវនកម្មលើរបាយការណ៍
ចំណាយរបស់ខ្លួន។

ទម្លាក់ថវិការដ្ឋទេយ្យបុរេប្រទានជុំដំបូងស្មើនឹងមួយជុំនៃឆ្នាំចាស់។ ក្រោយមកអង្គភាពថវិកានីមួយៗ រៀបចំចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ស្នើសុំធានាចំណាយ ស្នើសុំបុរេប្រទាន និងបោះផ្សាយអាណត្តិកម្មទូទាត់ការចំណាយទាំងនោះ។

ពិតណាស់ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបាននូវបទពិសោធន៍យ៉ាងច្រើន ជាពិសេស ការពើបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដែលសុទ្ធសឹងជាបញ្ហាថ្មីៗនិងបញ្ហាប្រឈមដែលធ្លាប់កើតមានក្នុងការអនុវត្តថវិកាតាមមាតិកាសេដ្ឋកិច្ច។ ក្នុងន័យនេះ ការរៀបចំសកម្មភាព នៅមិនទាន់បន្សីជាមួយចង្កោមសកម្មភាព ដើម្បីឈានទៅសម្រេចសូចនាកររបស់អនុកម្មវិធី និងកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួងទាំងមូល នៅឡើយ ដែលនេះ ជាបញ្ហាស្នូលនៃការអនុវត្តថវិកាកម្មវិធី។ ប្រសិនបើការគ្រោងថវិកាសម្រាប់អនុវត្តសកម្មភាព ដែលមិនចូលរួមចំណែកសម្រេចសូចនាកររបស់ចង្កោមសកម្មភាពនោះទេ វានឹងមិនអាចឈានទៅសម្រេចគោលដៅកម្មវិធីរួមបានឡើយ។ បញ្ហាស្ថិតត្រង់ថាមន្ត្រីរៀបចំផែនការថវិកាមិនបានស្វែងយល់ឱ្យបានច្បាស់លាស់ពីគោលបំណងគោលនយោបាយ និងសូចនាករនៃកម្មវិធីរបស់ខ្លួននៅឡើយ។ ម្យ៉ាងទៀត ការចូលរួមរៀបចំថវិកាពីសំណាក់ប្រធានកម្មវិធី និងប្រធានអនុកម្មវិធី នៅមានកម្រិត មានន័យថាមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុទាំងអស់ជាអ្នករៀបចំសកម្មភាពតែ





ម្នាក់ឯង។ ក្រុមការងាររៀបចំថវិការបស់ក្រសួងក៏ពុំទាន់សហការគ្នាបានល្អក្នុងការរៀបចំគម្រោងថវិកាផងដែរ។ លើសពីនេះ នាយកដ្ឋានហិរញ្ញវត្ថុ ជាក្រុមការងារសរុបថវិការួមរបស់ក្រសួង ហើយនាយក-ដ្ឋានផែនការ ជាក្រុមការងារសរុបផែនការសកម្មភាពរបស់ក្រសួង។ ឧទាហរណ៍ ក្នុងឆ្នាំ២០១៥ មានការធ្វើនិយ័តកម្មមិនតិចជាង ២០ឡើយ ពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយទៀត, ពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយទៀត និងពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត។

ជាមួយគ្នានេះ កង្វះខាតធនធានមនុស្សជំនាញលើថវិកាកម្មវិធី នៅអង្គភាពថវិកា



បូករួមនឹងតារាងសម្រាប់បំពេញគម្រោងថវិកាប្រចាំឆ្នាំដែលភ្ជាប់ជាមួយសារាចរណែនាំ មានលក្ខណៈស្មុគស្មាញ និងមានចំនួនច្រើនពេកនោះ បានធ្វើឱ្យការរៀបចំ និងការអនុវត្តថវិកាកម្មវិធី មិនអាចដំណើរការទៅបានរលូន និងត្រូវចំណាយពេលវេលាច្រើន។

ជាការពិត ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីចាប់តាំងពីឆ្នាំ២០០៧ ដែលអង្គភាពនីមួយៗ មានមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុរួចហើយ ប៉ុន្តែអ្វីដែលប្រែប្រួលសំខាន់ចាប់ពីឆ្នាំ២០១៥ នេះ គឺអង្គភាពថវិកាត្រូវរ៉ាប់រងលើការគ្រប់គ្រងថវិកាទាំងមូលដោយខ្លួនឯងផ្ទាល់។ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងចំណាយ និងការគ្រប់គ្រងសាច់ប្រាក់ សុទ្ធតែទាមទារឱ្យមានចំណេះដឹងខាងផ្នែកហិរញ្ញវត្ថុច្បាស់លាស់ ដើម្បីធានាថាមានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាក្នុងការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញ។ ភាពស៊ីសង្វាក់នៃប្រព័ន្ធគ្រប់គ្រងថវិកាតាមកម្មវិធី ចាប់ពីមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ទៅប្រធានអង្គភាពថវិកា និងរហូតដល់ប្រធានកម្មវិធី គឺពុំទាន់យល់ដឹងពីតួនាទីរបស់ខ្លួនច្បាស់លាស់នៅឡើយ ដែលជាហេតុធ្វើការគ្រោងថវិកា និងការអនុវត្តថវិកា មិនអាចសម្រេចបានតាមគោលដៅ។ សមត្ថភាពគ្រប់គ្រងរបស់ប្រធានអនុកម្មវិធី (អង្គភាពថវិកា) ក៏ជាផ្នែកមួយនៃការកំណត់នូវភាពជោគ-ជ័យនៃការអនុវត្តថវិកាកម្មវិធីផងដែរ ពី-ព្រោះសិទ្ធិអំណាច និងការទទួលខុសត្រូវទាំងឡាយនៃការគ្រប់គ្រងថវិកាកម្មវិធី ត្រូវបានផ្តល់ជូនប្រធានអនុកម្មវិធីផ្ទាល់តែម្តង។

នៅពេលអនុវត្តថវិកា ទោះបីជានីតិវិធីនៃការអនុវត្តថវិកានៅដដែលក៏ដោយ តែអ្នកអនុវត្តថ្មីនៅអង្គភាពថវិកា បានបង្កើតឱ្យមានភាពលំបាក និងចំណាយពេលវេលាច្រើនក្នុងការស្នើសុំចំណាយ និងការទូទាត់

ថវិកា ដែលទាមទារឱ្យមានភាពអត់ធ្មត់ខ្ពស់សម្រាប់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ។ ភាពស្មុគស្មាញ និងចំណាយពេលវេលាច្រើននៃនីតិវិធីស្នើសុំចំណាយ និងទូទាត់ចំណាយ បានធ្វើឱ្យអង្គភាពថវិកាខ្លះ មិនមានឆន្ទៈក្នុងការចំណាយថវិកាកម្មវិធីនេះឡើយ។ ដូចនេះ ការវិវឌ្ឍ ឬកែសម្រួលច្បាប់សារាចរ និងការណែនាំថ្មីៗ ទាមទារនូវពេលវេលា ការយល់ដឹង និងការរៀនសូត្រខ្ពស់។

ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៃការអនុវត្តថវិកាកម្មវិធីនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ដូចជាមិនទាន់មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ឡើយ។ នាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ នៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ ដែលទើបតែត្រូវបានបង្កើត នៅត្រូវរៀនសូត្រច្រើនទៀត លើការត្រួតពិនិត្យតាមដានលទ្ធផលសម្រេចបាននៃសូចនាករតាមកម្មវិធី។ តួនាទីរបស់នាយកដ្ឋាននេះ គួរតែត្រូវបានពង្រឹង ពីព្រោះលទ្ធផលពីការត្រួតពិនិត្យ និងតាមដាន អាចជាមូលដ្ឋានចំបងក្នុងការធ្វើសេចក្តីសម្រេចចិត្តទាន់ពេលវេលាក្នុងដំណើរការអនុវត្តថវិកានេះឱ្យមានប្រសិទ្ធភាព និងត្រូវបានយកធ្វើជាមូលដ្ឋានសម្រាប់ការគ្រោងកញ្ចប់ថវិកានៅឆ្នាំបន្តបន្ទាប់។

នាយកដ្ឋានហិរញ្ញវត្ថុ បានព្យាយាមសម្របសម្រួលស្វែងរកយន្តការជាច្រើន ដើម្បីឱ្យដំណើរការអនុវត្តថវិកាកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា អាចដំណើរការទៅបានល្អ។ ការប្រជុំស្វែងរកបញ្ហាប្រឈមនានា ត្រូវបានរៀបចំជាច្រើនលើកច្រើនសារ និងបានរៀបចំកិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើតយន្តការដោះស្រាយបញ្ហាប្រឈមទាំងនោះ។ ប្រកាសអន្តរក្រសួងមួយចំនួនរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ត្រូវបានបង្កើតឡើងដើម្បីពន្លឿននីតិវិធីអនុវត្តថវិកាផងដែរ។

ទោះបីជាយន្តការដោះស្រាយជាច្រើនត្រូវបានដាក់ចេញ ក៏ប៉ុន្តែ ទន្ទឹមនេះ ក្រសួងអប់រំ យុវជន និងកីឡា គួរតែរៀបចំបង្កើតជាយន្តការរួមមួយដើម្បីឱ្យការបំពេញការងារមានភាពប្រទាក់ក្រឡាគ្នា និងអាចសម្រេចបានតាមគោលដៅ។ ជំហានដំបូងដែលគួរតែគិតគូរជាបន្ទាន់ គឺរៀបចំជាក្រុមការងារមួយដែលមានសមាសភាពពីក្រុមការងាររៀបចំថវិកា ក្រុមការងារអនុវត្តថវិកា និងក្រុមការងារតាមដានត្រួតពិនិត្យ។ ពេលនោះមន្ត្រីគ្រប់គ្រងថវិកាកម្មវិធីពាក់ព័ន្ធទាំងអស់ នឹងមានកិច្ចសហការគ្នា បានកាន់តែល្អ យល់ដឹងពីតួនាទីរបស់ខ្លួនបានកាន់តែខ្លាំង និងអាចរៀបចំជាប្រព័ន្ធការងារមួយដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ ក្រុមការងារ គួរតែរៀបចំពង្រឹងការរៀបចំផែនការថវិកាបីឆ្នាំរំកិល ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ នោះនៅពេលដែលក្រសួងរៀបចំថវិកាប្រចាំឆ្នាំ នឹងមិនចំណាយពេលវេលាច្រើនឡើយ ដោយក្រសួងអាចយកផែនការថវិកាបីឆ្នាំរំកិលដែលមានស្រាប់តែម្តង ធ្វើជាមូលដ្ឋានក្នុងការរៀបចំ។ បន្ទាប់មកនៅពេលអនុវត្ត ក្រុមការងារគួរតែរៀបចំប្រព័ន្ធតាមដានការអនុវត្តថវិកាមួយដែលអាចផ្តល់នូវរបាយការណ៍ថវិកាដែលមានលក្ខណៈសុក្រិតនិងទាន់ពេលវេលា។ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលសូចនាករពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ ក៏គួរតែពង្រឹងដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ ■

# សារៈប្រយោជន៍នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មកលើអភិបាលកិច្ចល្អ

សេចក្តីត្រូវការរបស់សង្គមតែងតែមានទំហំធំជាងធនធានដែលរដ្ឋមាន ដែលទាមទារឱ្យមានជាចាំបាច់នូវការគ្រប់គ្រងប្រកបដោយស័ក្តិសិទ្ធិភាពបំផុត និងកាត់បន្ថយភាពខ្ជះខ្ជាយឱ្យបានជាអតិបរមា។ ដូចនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលដៅដើម្បីធានាថាចំណូលដែលប្រមូលបាន ត្រូវបានចាយទៅវិញប្រកបដោយប្រសិទ្ធភាព។




យ៉ាងណាមិញ ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកត្តាបង្កើនសេចក្តីទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើការអនុវត្តរបស់រដ្ឋាភិបាល។ ក្នុងបរិការណ៍នេះ នៅប្រទេសកំពុងអភិវឌ្ឍន៍ ការកែទម្រង់លើកិច្ចដំណើរការ ឬក៏ស្ថាប័នគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាមានសារៈសំខាន់ សម្រាប់ធានាដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការប្រើប្រាស់ធនធានសាធារណៈប្រកបដោយស័ក្តិសិទ្ធិភាព, ការបង្កើនតម្លាភាព និងគណនេយ្យភាពសម្រាប់ហិរញ្ញវត្ថុរបស់រដ្ឋ និងជាពិសេសការបង្កើនគុណភាពសេវាសាធារណៈ ដែលគោលដៅទាំងនេះគឺសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋរបស់ខ្លួន ។

ជាទូទៅ សម្រាប់ប្រទេសដែលបានកំណត់ និងដាក់ចេញនូវការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងតែទទួលរងនូវផលប៉ះពាល់ជាវិជ្ជមាន និងពើបប្រទះនូវបញ្ហាប្រឈមគន្លឹះនានា ដែលត្រូវដោះស្រាយ។ តាមរយៈអត្ថបទនេះ នឹងបង្ហាញឱ្យឃើញពីសារប្រយោជន៍នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ អភិបាលកិច្ចល្អ, ការពង្រឹងតួនាទីសវនកម្មជាតិ និងការប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យា គឺជាមូលដ្ឋានដែលត្រូវអនុវត្តជាចាំបាច់។

តាមការស្រាវជ្រាវ និងការវាយតម្លៃ ពីឯកសារសិក្សានានា បង្ហាញថាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្តល់

វិភាគទានយ៉ាងសំខាន់ទៅលើការលើកកម្ពស់តម្លាភាព និងការកាត់បន្ថយនៃអំពើពុករលួយ តួយ៉ាងដូចជា៖

- ប្រព័ន្ធកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដំណើរការល្អ និងធ្វើឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់មានគណនេយ្យភាពចំពោះសភា សវនកម្មជាតិ និងសាធារណៈផង
- ជំរុញឱ្យមានការធ្វើប្រតិភូកម្មអំណាច និងការបែងចែកតួនាទីច្បាស់លាស់ ជាមួយនឹងយន្តការការងារជាក់លាក់
- បង្កើនតម្លាភាពតាមរយៈការផ្តល់ព័ត៌មានបានទូលាយ រហ័ស និងសុក្រឹតភាពប្រកបដោយបូរណភាព និងឯករាជ្យភាព។

**អភិបាលកិច្ចល្អ, ការពង្រឹងតួនាទីសវនកម្មជាតិ និងការប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យា គឺជាមូលដ្ឋានដែលត្រូវអនុវត្តជាចាំបាច់ ។**

ម៉្យាងវិញទៀត លទ្ធផលនៃការងារកែទម្រង់នេះ ត្រូវបានសន្និដ្ឋានជារួម នូវផលប៉ះពាល់ជាវិជ្ជមានរួមមាន៖ (១) ជាឧបករណ៍ចម្បងសម្រាប់កាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព (២) លើកកម្ពស់វប្បធម៌សន្ទនា (៣) ពង្រឹងយន្តការនៃការត្រួតពិនិត្យហិរញ្ញវត្ថុ និងវិស័យថវិកា (៤) បង្កើនភាពជាម្ចាស់របស់រដ្ឋាភិបាល និងបូរណភាព។

ស្របពេលដែលសហគមន៍អន្តរជាតិចាប់ផ្តើមមានការចាប់អារម្មណ៍ខ្លាំងទៅលើកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានឧបករណ៍នៃការវិភាគជាច្រើន ត្រូវបានបង្កើតឡើង ដើម្បីវិភាគទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងចំណោមនោះ ឧបករណ៍វិភាគមួយត្រូវបានមជ្ឈដ្ឋានទូទៅឱ្យតម្លៃខ្លាំងជាងគេនោះ គឺឧបករណ៍គណនេយ្យភាពហិរញ្ញវត្ថុ និងការចំណាយសាធារណៈ (PEFA) ដែលត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ ២០០៥។ PEFA បានក្លាយជាឧបករណ៍ស្តង់ដារនៃការវាស់ស្ទង់ ដែលមានរយៈពេលវាយតម្លៃច្បាស់លាស់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ផ្អែកលើសូចនាករគន្លឹះទាំង២៨ ដោយផ្តល់នូវព័ត៌មានជាក់លាក់ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាការពិតការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើរតួនាទីសំខាន់សម្រាប់ បម្រើឱ្យគោលនយោបាយរបស់រដ្ឋាភិបាល។ ក្នុងបរិការណ៍នេះ ឥទ្ធិពលសំខាន់ចំនួន ៤ ដែលកើតឡើងដោយផ្ទាល់អំពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះគឺ៖

**១. គណនេយ្យភាព ៖** ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជួយជំរុញគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ឱ្យមានគណនេយ្យភាពជាមួយគ្នា ក្នុងការអនុវត្តកម្មវិធីរបស់រដ្ឋាភិបាល និងទំនួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ក្នុងន័យនេះ តួអង្គទាំងនោះមិនត្រឹមតែមានវិន័យក្នុងការអនុវត្តថវិកាតែប៉ុណ្ណោះទេ តែថែមទាំងប្រើប្រាស់ធនធានប្រកបដោយភាពសន្សំសំចៃ ព្រមទាំងការកំណត់អាទិភាពចំណាយប្រកបដោយភាពទាន់ពេលវេលា។

**២. ការធ្វើប្រតិភូកម្មអំណាច៖** ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធ្វើឱ្យមានការកាត់បន្ថយអំណាចដែលធ្លាប់តែប្រមូលផ្តុំ ដោយផ្តោតជាសំខាន់ទៅលើយន្តការត្រួតពិនិត្យ



និងការបែងចែកការងារច្បាស់លាស់ជៀសវាងការជាន់មុខងារគ្នារវាងអង្គភាពតែមួយផង និងរវាងស្ថាប័ននិងស្ថាប័នផង។ ជារួម តួនាទីសភា រដ្ឋាភិបាល និងសវនកម្មមានតួនាទីផ្សេងៗគ្នា តែបំពេញមុខងារឱ្យគ្នាទៅវិញទៅមក។ ឈរលើយន្តការ Check and Balance, ប្រព័ន្ធ និងកិច្ចដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ មិនអាចអនុវត្តទៅបានដោយគ្មានការកំណត់មុខងារច្បាស់លាស់សម្រាប់គ្រប់តួអង្គទាំងអស់បាននោះទេ ។

**៣. ការចូលរួមរបស់ប្រជាជន និងវិមជ្ឈការ៖** គោលការណ៍តម្លាភាព និងភាពរហ័សនៃព័ត៌មាន គឺជាធាតុដ៏សំខាន់ ប៉ុន្តែ មិនមែនសុទ្ធតែត្រូវឈរលើមូលដ្ឋាននៃការបើកចំហរ ឬសេរីភាពនៃការទទួលបានព័ត៌មាន



គ្រប់ជ្រុងជ្រោយនោះទេ។ ទោះជាយ៉ាងណាការចូលរួមចំណែកពីគ្រប់តួអង្គ ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ គឺជាកត្តាមិនអាចខ្វះបាន,រីឯការធ្វើវិមជ្ឈការហិរញ្ញវត្ថុក៏ជាកត្តាចូលរួមចំណែកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានន័យថា រាល់ការផ្ទេរធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ត្រូវការជាចាំបាច់នូវការយល់ដឹងអំពីអាទិភាពនៃសកម្មភាពដែលត្រូវអនុវត្ត និងសមត្ថភាពនៃការអនុវត្តដោយគោរពវិន័យថវិកា។ ជារួម ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវការពង្រឹងរហូតដល់ថ្នាក់ក្រោមជាតិ ដើម្បីធានាដល់គោលនយោបាយវិមជ្ឈការដោយជោគជ័យ។

**៤. គោលជំហររបស់រដ្ឋាភិបាល÷** ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពលើការអនុវត្តសកម្មភាពរបស់រដ្ឋាភិបាល ក៏ដូចជាការពង្រឹងភាពស្របច្បាប់របស់រដ្ឋមួយ សំដៅដល់ការកាត់បន្ថយអំពើពុករលួយ និងភាពអសកម្ម។ ការកែលម្អប្រសិទ្ធភាពនៃវដ្តថវិកាគឺជាផ្នែកមួយនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងន័យនេះ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋាភិបាលត្រូវទទួលខុសត្រូវដោយធ្វើយ៉ាងណាឱ្យសកម្មភាពអាទិភាព ត្រូវបានអនុវត្តដោយខ្ជាប់ខ្ជួន ហើយធានាថារាល់ការចំណាយអនុវត្តទៅដោយរលូន និងចំទិសដៅ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ភាគច្រើនតែងជួបប្រទះបញ្ហាប្រឈមលើការអនុវត្តថវិកា ពោលគឺការអនុវត្តថវិកាពុំមានប្រសិទ្ធភាពដោយការអនុវត្តចំណាយមិនចំទិសដៅ។ លទ្ធផលនេះ ត្រូវបានពន្យល់លើមូលហេតុដូចជា កត្តាសមត្ថភាពអនុវត្តចំណាយ ឬកិច្ចលទ្ធកម្ម, ការធ្វើផែនការថវិកាមិនល្អដែលជះឥទ្ធិពលអវិជ្ជមានដល់ប្រសិទ្ធភាពនៃការអនុវត្តថវិកា, រីឯការចំណាយពុំបានគ្រោងទុកមានទំហំច្រើនហួសហេតុពេក ក៏ជាកត្តាធ្វើឱ្យការវិភាជថវិកាពុំមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពផងដែរ។

ហេតុដូចនេះ ផ្អែកលើកត្តា ដូចដែលបានរៀបរាប់ខាងលើនេះហើយ ទើបមជ្ឈដ្ឋានទូទៅច្រើនសន្និដ្ឋានថា ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវការប្រើរយៈពេលយូរ ។ ប្រទេសដែលធ្លាប់តែអនុវត្តប្រព័ន្ធថវិកាតាមជំពូកគណនី ឬអនុគណនី មានលក្ខណៈមជ្ឈការច្រើន តែងពុំសូវចាប់អារម្មណ៍លើសារៈប្រយោជន៍នៃការកែទម្រង់នោះឡើយ ព្រោះដោយយល់ឃើញថាការកែទម្រង់នឹងគំរាមកំហែងដល់ប្រព័ន្ធមួយដែលមានលក្ខណៈមជ្ឈការខ្លាំង និងពុំសូវប្រើប្រាស់ប្រព័ន្ធប្រជាធិបតេយ្យ។ ឆន្ទៈនយោបាយរបស់រដ្ឋាភិបាលគឺជាកត្តាចម្បងសម្រាប់នាំការងារកែទម្រង់ប្រកបដោយភាពជោគជ័យ ហើយការចូលរួម និងការលះបង់ពេលវេលាសម្រាប់ការងារកែទម្រង់ គឺជាលក្ខខណ្ឌចាំបាច់ផងដែរ។ លើសពីនេះ ក្រសួងហិរញ្ញវត្ថុតែងតែដើរតួនាទីដ៏សំខាន់ជាសេនាធិការរបស់រដ្ឋាភិបាលក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការកំណត់នូវគោលនយោបាយ និងពង្រឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ប៉ុន្តែការងារកែទម្រង់គឺជាការងារដែលទាមទារនូវពេលវេលា និងរយៈពេលយូរដើម្បីសម្រេចបាននូវគោលដៅចុងក្រោយដែលតម្រូវឱ្យគ្រប់តួអង្គមានភាពអត់ធ្មត់ និងឆន្ទៈខ្ពស់។ ■

# ក្រុមការងាររៀបចំព្រឹត្តិបត្រ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.)

- **រស់ សីលវ៉ា** — អគ្គលេខាធិការ នៃ **អ.គ.ហ.**
- បណ្ឌិត **ហ៊ែល ចំរើន** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **មាស សុខសេនសាន** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **ប៉ែន ធីរុទ្ធ** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **ប៊ូ វឌ្ឍសុខា** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **យ៉េត វិណែល** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **អ៊ុង លុយណា** — អគ្គលេខាធិការរង នៃ **អ.គ.ហ.**
- **អ៊ុំ យុទ្ធី** — ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ត្រួតពិនិត្យ និងវាយតម្លៃ នៃ **អ.គ.ហ.**
- **សុគន្ធ ចរិយា** — មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- **ឆៀង សុខតីរម្យ** — មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- **លី វ៉ុង** — មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.**
- **អ៊ុច សោភ័ណ** — មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ នៃ **អ.គ.ហ.**
- **យន ម៉ាលីមឆេង** — មន្ត្រីថវិកា នៃ **អ.គ.ហ.**
- **ប្រាំង ឧត្តម** — មន្ត្រីជំនាញ នៃ **អ.គ.ហ.**
- **ប៊ុម លៃហេង** — មន្ត្រីជំនាញ នៃ **អ.គ.ហ.**
- **អ៊ុង មករា** — មន្ត្រីជំនាញ នៃ **អ.គ.ហ.**

## អាសយដ្ឋានទំនាក់ទំនង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៤៣០ ៧៩១
ទូរសារ: (៨៥៥) ២៣ ៤៣០ ៧៤៥
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm